# ព្រឹត្តិបត្រព័ត៌មានលេខ ០៧
## (មេសា-មិថុនា ២០២៣)

# Newsletter Issue 07
## (April-June 2023)

ចេញផ្សាយលើកទី២



**នៅក្នុងលេខនេះ | In this Issue**


- ការធ្វើបច្ចុប្បន្នភាពគម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី (WEGS)
  Update on Women Entrepreneurs Guarantee Scheme (WEGS)
- សេចក្តីប្រកាសព័ត៌មាន ប្រកាសស្តីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ របស់ធនាគារជាតិនៃកម្ពុជា
  Press Release – Prakas on Credit Risk for Capital Adequacy Ratios in Deposit-Taking Banks and Financial Institutions of National Bank of Cambodia
- អត្ថបទស្វែងយល់ពីហានិភ័យការជ្រើសរើស និងហានិភ័យចិត្តសាស្ត្រ
  Understanding Adverse Selection and Moral Hazard
- បទពិសោធន៍របស់លោកស្រី ប៉ែន បុប្ផា ម្ចាស់អាជីវកម្មដែលទទួលបានកម្ចីដែលមានការធានាពី CGCC
  Meet with Ms. Pen Bopha, Business Owner Who Received a Loan Guaranteed by CGCC

# មាតិកា | Contents


សេចក្តីផ្តើម | Introduction ---- 02
វឌ្ឍនភាពការធានាឥណទាន | Credit Guarantee Progress ---- 07
កិច្ចសហប្រតិបត្តិការ និងសកម្មភាពនានា | Cooperation and Activities ---- 10
ការស្វែងយល់អំពីការធានាឥណទាន | Understanding Credit Guarantee ---- 17
ដៃគូរបស់យើង | Our Partners ---- 22


# ក្រុមការងារព្រឹត្តិបត្រព័ត៌មាន | Newsletter Editorial Team

## រៀបរៀងដោយ | Prepared by:

| | |
|---|---|
| លោក ណូ លីដា<br>Mr. No Lida | អគ្គនាយករង<br>Deputy Chief Executive Officer |
| លោកស្រី ពិន ម៉ានីកា<br>Ms. Pin Manika | ប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម<br>Manager of Marketing and Business Development |
| លោកស្រី សាន សុខរីណា<br>Ms. San Sokrina | ប្រធានការិយាល័យអភិវឌ្ឍន៍ផលិតផល<br>Manager of Product Development |
| កញ្ញា សន ឆវីវតី<br>Ms. Sorn Chhorvyvatey | អនុប្រធានការិយាល័យទីផ្សារ និងទំនាក់ទំនង<br>Deputy Manager of Marketing and Communication |
| លោក សែ គឹមវាសនា<br>Mr. Se Kimveasna | បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកទីផ្សារ និងទំនាក់ទំនង<br>Senior Executive of Marketing and Communication |
| លោក គឹម ហេងបំណង<br>Mr. Kim Hengbomnorng | បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកទីផ្សារ និងយុទ្ធនាការ<br>Senior Executive of Marketing & Campaign |
| លោកស្រី សុខ ចរិយា<br>Ms. Sok Chakriya | បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកទំនាក់ទំនង<br>Senior Executive of Relationship Management |

## ចូលរួមផ្តល់មាតិកាដោយ | Contributed Contents by:

| | |
|---|---|
| លោក មួង សុខប៊ូ<br>Mr. Mourng Sokbou | ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា<br>Director of Information Technology Services Department |

## រចនាដោយ | Designed by:

| | |
|---|---|
| លោក នង សុគន្ធា<br>Mr. Nong Sokunthea | បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកមាតិកា និងរចនាក្រាហ្វិក<br>Senior Executive of Creative Contents and Graphic Designer |

## ត្រួតពិនិត្យដោយ | Reviewed by:

| | |
|---|---|
| លោក **KL Wong**<br>Mr. KL Wong | អគ្គនាយក<br>Chief Executive Officer |

# សេចក្តីផ្តើម | Introduction

## សាររបស់អគ្គនាយក | Message from CEO



As we enter the 2nd quarter of the year, we celebrated the Khmer New Year in April, which is one of the most important and widely celebrated festivals in the country. It marks the beginning of a new year based on traditional Khmer lunar calendar. This year's celebration was special as many streets and public spaces were decorated and filled with many people who came out to celebrate to welcome the New Year. It was memorable for me as it was a time of joy, togetherness, unity and hope for a promising future as everyone came together to seek for a blessed and prosperous year.

In May, Cambodia was host to the 32nd Southeast Asian (SEA) Games and the 12th ASEAN Para Games where the games were held in Phnom Penh, Siem Reap, Sihanoukville, Kampot and Kep. It was the first time for Cambodia to be the host of both the games. The SEA Games was held over 2 weeks in May and followed by the Para Games in the first week of June.

The Games were well organized and attracted more than 12,400 sport delegates from 11 countries. The opening and closing ceremonies were spectacular and impressive!! Well done for such a grand and historic event.

Despite the celebrations, we managed to issue 291 guarantees amounting to $19.4mil guaranteed loans for the 2nd quarter. The momentum is good for the first half of the year, but the run rate is below our 2023 target ie. approximately 40% of 1,500 guarantees and $100mil guaranteed loans. We hope to have a stronger second half of the year.

During this quarter, we focused on strengthening our networking with business associations and our outreach programs to provinces. In April, we signed a MoU with the Cambodia Chamber of Commerce (CCC), an established business chambers with many segments of SMEs. We hope to assist their members to overcome financing challenges by promoting access to guaranteed loans.

We also entered into a strategic partnership with Maybank to provide trainings and workshop through the Bank's SME Building Capacity and Capability Program (BCC). The MoU is targeted towards the members of Business Network International (BNI-Super) and Cambodia Women Entrepreneurs Association (CWEA).

We paid a courtesy visit to the National Bank of Cambodia (NBC) to update on our progress and our close cooperation with our PFIs. We discussed the latest developments in the banking sector, NBC regulations and our outreach programs to support improvement and SME awareness in financial literacy. My sincere appreciation to H.E. Rath Sovannorak, Assistant Governor & Director General of Banking Supervision for his warm welcome and support.




Credit to Cambodia 2023

Our team continued with their outreach programs and visited Kampong Cham, Kampong Thom and Preah Vihear provinces. They conducted workshops with our PFIs and MSMEs on the role of credit guarantee and its benefits. Discussions were held with the PFI branch staff to improve their understanding of credit guarantee schemes and the process of submitting for guaranteed loan applications.

We also co-organized a seminar with CCC at Kampong Thom on "Guaranteed Loans to Support the Development of SMEs". It was a successful seminar attended by more than 100 SMEs from the 3 provinces. The positive feedback from the participants will steer the team to continue with their efforts to widen their outreach to more SMEs.

# អំពី ស.ធ.ក. | About CGCC

**សាជីវកម្មធានាឥណទានកម្ពុជា (CGCC)** គឺជាសហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០។ CGCC ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

CGCC ត្រូវបានចុះបញ្ជីជាផ្លូវការនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០ និងទទួលបានការគាំទ្របច្ចេកទេស ពីដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (WB) និងមូលនិធិអភិវឌ្ឍន៍ទុនរបស់អង្គការសហប្រជាជាតិ (UNCDF)។ CGCC បានដាក់ឱ្យដំណើរការនូវគម្រោងធានាឥណទានដំបូង នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១។

Credit Guarantee Corporation of Cambodia (CGCC) is a state-owned enterprise established by a Sub-Decree No. 140 ANKR.BK dated 01 September 2020. CGCC is operated under the technical and financial guidance of the Ministry of Economy and Finance (MEF).

CGCC was incorporated on 03 November 2020 and has been receiving technical support from Asian Development Bank (ADB), World Bank, and UN Capital Development Fund (UNCDF). CGCC launched the first guarantee scheme on 29 March 2021"

## ទស្សនវិស័យ | Vision

ក្លាយខ្លួនទៅជាស្ថាប័នធានាឥណទាននាំមុខគេនៅប្រទេសកម្ពុជា ក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងអភិវឌ្ឍសហគ្រាសខ្នាតតូចនិងមធ្យម។

To be the preferred credit guarantee institution in Cambodia to improve financial inclusion and develop the growth of SMEs.

## បេសសកម្ម | Mission

បេសកកម្មចម្បងរបស់CGCCគឺផ្តល់ការធានាឥណទានលើកម្ចីដែលផ្តល់ឱ្យអាជីវកម្ម ដើម្បីចែករំលែកហានិភ័យជាមួយស្ថាប័នផ្តល់កម្ចី និងបង្កើនបរិយាបន្នហិរញ្ញវត្ថុ។

To provide credit guarantees to lenders on loans made to businesses based on international standards to share the risk with lenders and to improve financial inclusion.

## សមិទ្ធផលសំខាន់ៗ |CGCC's Milestones

**១ កញ្ញា ២០២០**

ទទួលបានការអនុម័តលើអនុក្រឹត្យស្តីពីការបង្កើតសាជីវកម្មធានាឥណទានកម្ពុជា ពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**៣ វិច្ឆិកា ២០២០**

បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម

**៤ កុម្ភៈ ២០២១**

ទទួលបានដើមទុនដំបូងចំនួន ៨១០ប៊ីលានរៀល (សមមូលនឹងប្រមាណ ២០០លានដុល្លារ) ពីរាជរដ្ឋាភិបាល

**២៩ មីនា ២០២១**

បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានទី១ ហៅថា "គម្រោងធានាឥណទានដើម្បីស្តារអាជីវកម្ម" និងបានចុះកិច្ចព្រមព្រៀងធានាឥណទានជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមជំហានទី១ ដែលមាន ៧ស្ថាប័ន

**២៣ មេសា ២០២១**

បានផ្តល់ការធានាឥណទានជាលើកដំបូងលើកម្ចីទំហំ ១លានដុល្លារ

**២៩ មិថុនា ២០២១**

បានចុះកិច្ចព្រមព្រៀងធានាឥណទានជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមជំហានទី២ ដែលមាន ៨ស្ថាប័ន

**២២ កញ្ញា ២០២១**

បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានទី២ ហៅថា "គម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទាន" និងបានចុះកិច្ចព្រមព្រៀងធានាឥណទានជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមជំហានទី៣ ដែលមាន ៥ស្ថាប័ន

**៥ វិច្ឆិកា ២០២១**

ទទួលបានការលើកលែងអាករលើតម្លៃបន្ថែម (VAT) លើកម្រៃធានាឥណទាន

**១០ ធ្នូ ២០២១**

បានចុះកិច្ចព្រមព្រៀងធានាឥណទានជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម ជំហានទី៤ ដែលមាន ៣ស្ថាប័ន

**០១ មេសា ២០២២**

បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានទី៣ ហៅថា "គម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី" ដែលមានទំហំទឹកប្រាក់ ៣០លានដុល្លារ

**០១ មេសា ២០២២**

បានផ្លាស់មកកាន់ការិយាល័យថ្មី ដែលស្ថិតនៅជាន់ទី១៩នៃមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច

**១២ កក្កដា ២០២២**

បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទាន សម្រាប់វិស័យទេសចរណ៍

**០១ មករា ២០២៣**

ការបន្តសុពលភាពគម្រោងធានាឥណទានដើម្បីស្តារអាជីវកម្ម

**០១ មករា ២០២៣**

ការដាក់ឱ្យដំណើរការ "គម្រោងធានាឥណទានជាកញ្ចប់"

# ការធ្វើបច្ចុប្បន្នភាពគម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី | Update on Women Entrepreneurs Guarantee Scheme (WEGS)

KH គម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី គឺជាគម្រោងធានាឥណទានទី៣របស់ CGCC ដែលបានដាក់ចេញក្នុងខែមេសា ឆ្នាំ២០២២ ក្នុងគោលបំណងបង្កើនការគាំទ្រដល់សហគ្រិនស្ត្រី និងអាជីវកម្មដែលគ្រប់គ្រង និងដឹកនាំដោយស្ត្រី ឱ្យទទួលបានកម្ចីដែលមានការធានាពី CGCC ដែលផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) ជាមួយនឹងវិសាលភាពនៃការធានាខ្ពស់ និងកម្រៃធានាឥណទានទាប ព្រមទាំងលក្ខខណ្ឌអនុគ្រោះជាច្រើនទៀត។

ក្នុងខួប ១ឆ្នាំ នៃគម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី ក្នុងខែមេសា ឆ្នាំ២០២៣ CGCC បានធ្វើបច្ចុប្បន្នភាពគម្រោងនេះ ដូចមានក្នុងតារាងខាងក្រោម៖

| | |
|---|---|
| ទំហំគម្រោង | ៣០ លានដុល្លារ |
| រយៈពេលនៃគម្រោង | ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ |
| ប្រភេទនៃការធានា | ការធានាឯកត្តឥណទាន |
| ប្រភេទនៃកម្ចី | • គ្រប់ប្រភេទកម្ចី (កម្ចីមានកាលកំណត់, ឥណទានវិបារូបរ៍, ឥណទានពាណិជ្ជកម្ម ។ល។)<br>• សម្រាប់តែកម្ចីថ្មី មិនអាចប្រើប្រាស់សម្រាប់ហិរញ្ញប្បទានសារឡើងវិញ<br>• កម្ចីដែលមានទ្រព្យធានា និងកម្ចីគ្មានទ្រព្យធានា<br>• លើកលែងកម្ចី ដែលប្រើប្រាស់សម្រាប់អាជីវកម្មដែលត្រូវបានហាមឃាត់ (មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១ នៃគោលការណ៍ណែនាំរបស់គម្រោង) |
| វិសាលភាពនៃការធានា | ៨០% នៃប្រាក់ដើម |
| កម្រៃធានានៅឆ្នាំទី១ | ១% នៃកម្ចីដែលត្រូវបានធានា<br>(៥០% នៃថ្លៃសេវានេះនឹងត្រូវបានការឧបត្ថម្ភ) |

| | | | |
|---|---|---|---|
| កម្រៃធានានៅឆ្នាំទី២ តទៅ | ១% នៃកម្ចីដែលត្រូវបានធានា | | |
| រយៈពេលនៃការធានា | អតិបរមា ៧ឆ្នាំ | | |
| អត្រាការប្រាក់អតិបរមានៅឆ្នាំដំបូង (រួមបញ្ចូលកម្រៃធានានៅឆ្នាំដំបូង) | សម្រាប់ធនាគារ | កម្ចីជាប្រាក់រៀល<br>កម្ចីជាប្រាក់ដុល្លារ | ៨%<br>៩% |
| | សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | កម្ចីជាប្រាក់រៀល<br>កម្ចីជាប្រាក់ដុល្លារ | ១០%<br>១១% |
| ទំហំជាអតិបរមាសម្រាប់កម្ចីនីមួយៗ | គោលបំណងនៃកម្ចី | MSME | |
| | ទុនបង្វិល | ៣០០.០០០ ដុល្លារអាមេរិក | |
| | វិនិយោគ / ពង្រីកអាជីវកម្ម | ៥០០.០០០ ដុល្លារអាមេរិក | |
| លក្ខខណ្ឌផ្សេងៗ | លក្ខខណ្ឌផ្សេងទៀតនៃ WEGS រួមទាំងការរៀបចំឥណទានឡើងវិញ ការស្តារប្រាក់កម្ចី និងនីតិវិធីទាមទារសំណង ត្រូវបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងធានាឥណទាន។ | | |

ព័ត៌មានលម្អិតនៃលក្ខខណ្ឌគម្រោងធានាឥណទានសហគ្រិនស្ត្រី សូមចូលទៅកាន់គេហទំព័ររបស់ CGCC ៖ http://bitly.ws/KCbt

EN Women Entrepreneurs Guarantee Scheme (WEGS), the third credit guarantee scheme offered by the CGCC, is specifically designed for women and women-owned SMEs to obtain guaranteed loans by CGCC through Participating Financial Institutions (PFIs) with higher guarantee coverage and a lower guarantee fee for all sectors as well as other favorable features.

On the 1-Year Anniversary of WEGS in April 2023, CGCC has updated the scheme features as the below table:

| | |
|---|---|
| Scheme Size | USD 30 million |
| Effective Date | 17 April 2023 |
| Type of Guarantee | Individual Loan Guarantee |
| Eligible Loan | • All types of loan facility (term loan, overdraft, trade facility, etc.)<br>• New loans ONLY, not for refinancing<br>• Both secured and unsecured loans<br>• Excluding loans in the Negative List |
| Guarantee Coverage | 80% of Outstanding Loan Principal |
| Guarantee Fee for the first year | 1% of Outstanding Guaranteed Amount<br>(50% of this fee will be subsidized) |

| | | | |
|---|---|---|---|
| Guarantee Fee for the Second year onward | 1% of Outstanding Guaranteed Amount | | |
| Guarantee Tenure | Maximum of 7 Years | | |
| First-Year Interest Rate Ceiling (Inclusive of First-Year Guarantee) | For Bank | KHR Loan<br>USD Loan | 8%<br>9% |
| | For MDI & MFI | KHR Loan<br>USD Loan | 10%<br>11% |
| Maximum Loan Amount (USD) | Loan Purposes | MSME | |
| | Working Capital | USD 300,000 | |
| | Investment/Business Expansion | USD 500,000 | |
| Other Conditions | Other conditions of the WEGS, including loan restructuring, loan recovery, and claim procedure, are specified in the Credit Guarantee Agreement. | | |

For detail of the WEGS scheme features, please go to CGCC's website: http://bitly.ws/KCbt

# ជួបជាមួយបុគ្គលិករបស់ CGCC | Meeting with CGCC's Employee



**លោក មួង សុខប៊ូ ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា**
**Mr. Mourng Sokbou, Director of Information Technology Services Department**

KH ជាមួយបទពិសោធន៍ជាង១៥ឆ្នាំក្នុងវិស័យធនាគារខ្ញុំបានទទួលនូវជំនាញដ៏ទូលំទូលាយផ្នែកព័ត៌មានវិទ្យា រួមមាន ការគ្រប់គ្រងទិន្នន័យ ការគ្រប់គ្រងប្រព័ន្ធស្នូលធនាគារ និងការគ្រប់គ្រងប្រតិបត្តិការព័ត៌មានវិទ្យា។ ខ្ញុំបានចាប់ផ្តើមអាជីពផ្នែកព័ត៌មានវិទ្យានៅឆ្នាំ២០០៧ នៅពេលខ្ញុំបានចូលបម្រើការងារនៅធនាគារមួយ ក្នុងតំណែងជាមន្ត្រីជំនួយផ្នែកព័ត៌មានវិទ្យាទូទៅ និងត្រូវបានតំឡើងតួនាទីជាអនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា។ ខ្ញុំក៏ជាសមាជិកនៃគណៈកម្មាធិការព័ត៌មានវិទ្យា ដោយមានភារកិច្ចធានានិរន្តភាពប្រតិបត្តិការនៃប្រព័ន្ធស្នូលធនាគារ និងការអនុវត្តស្តង់ដារ និងគោលនយោបាយព័ត៌មានវិទ្យាផងដែរ។

ខ្ញុំបានចូលបម្រើការងារនៅ CGCC នៅខែឧសភា ឆ្នាំ២០២១ ក្នុងនាមជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា ដើម្បីអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការធានាឥណទាន ពីចំណុចសូន្យ និងរៀបចំចក្ខុវិស័យ ព្រមទាំងយុទ្ធសាស្ត្រព័ត៌មានវិទ្យាសម្រាប់ក្រុមហ៊ុន។ ខ្ញុំត្រូវធានាឱ្យបាននូវស្តង់ដារដំណើរការល្អ សម្រាប់ប្រព័ន្ធព័ត៌មានវិទ្យាទាំងមូល ដោយសហការជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ។ ខ្ញុំក៏មានទំនួលខុសត្រូវលើផ្នែកសន្តិសុខព័ត៌មានវិទ្យា ការគ្រប់គ្រងគម្រោងការធានាអនុលោមភាពតាមស្តង់ដារខាងក្នុង និងខាងក្រៅ ការកសាង និងការដឹកនាំក្រុមអ្នកជំនាញផ្នែកព័ត៌មានវិទ្យា។

ខ្ញុំបានប្រើប្រាស់បទពិសោធន៍និងជំនាញរបស់ខ្ញុំ ដើម្បីអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យារបស់ CGCC ដោយផ្តោតលើការច្នៃប្រឌិតបច្ចេកវិទ្យា អនុលោមភាពនិងប្រសិទ្ធភាពប្រតិបត្តិការ។ ខ្ញុំមានគោលបំណងជំរុញ CGCC ឆ្ពោះទៅរកគោលដៅយុទ្ធសាស្ត្ររបស់ខ្លួន ដោយធានាឱ្យបាននូវហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាដែលមានសុវត្ថិភាព និងអាចជឿទុកចិត្តបាន។ ជាក់ស្តែង នាយកដ្ឋានព័ត៌មានវិទ្យា បានជ្រើសរើស និងដំឡើងប្រព័ន្ធមួយចំនួនដែលជួយសម្រួលប្រតិបត្តិការធានាឥណទាន ឱ្យមានតម្លាភាព និងប្រសិទ្ធភាព។ ពួកយើងលើកទឹកចិត្តដល់ការចែករំលែកព័ត៌មាន តាមរយៈការទំនាក់ទំនងជាក្រុម និងការសហការដែលអនុញ្ញាតឱ្យបុគ្គលិក CGCC ធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធភាព។ ពួកយើងប្រើប្រាស់ Microsoft Office 365 ដែលជួយសម្រួល និងធានាដល់ការទំនាក់ទំនងនៅក្នុង CGCC។

ការធ្វើការនៅ CGCC ផ្តល់ឱ្យខ្ញុំនូវបទពិសោធន៍ និងឱកាសដ៏មានតម្លៃជាច្រើនសម្រាប់ការរីកចម្រើន។ បរិយាកាសស្និទ្ធស្នាល ដែលបង្កដោយបុគ្គលិក និងថ្នាក់គ្រប់គ្រងកំពូលៗ រួមទាំងអគ្គនាយក អគ្គនាយករង និងក្រុមប្រឹក្សាភិបាល បានបង្កើតនូវបរិស្ថានការងារដែលមានការគាំទ្រ និងសហការគ្នាទៅវិញទៅមកបានយ៉ាងល្អ។ នៅ CGCC ខ្ញុំបានប្រឡូកនៅក្នុងក្រុមហ៊ុនមួយដែលមានចក្ខុវិស័យ បេសកកម្ម និងគោលដៅដ៏ច្បាស់លាស់។ ខ្ញុំមានឱកាសធ្វើការយ៉ាងទូលំទូលាយជាមួយអតិថិជន និងគម្រោងជាច្រើន ដែលអាចពង្រីកជំនាញ និងចំណេះដឹងរបស់ខ្ញុំបន្ថែមទៀត។ ***សម្រាប់ខ្ញុំ វប្បធម៌ការងារនៅ CGCC គឺលើកកម្ពស់ការច្នៃប្រឌិត ការងារជាក្រុម និងការអភិវឌ្ឍន៍វិជ្ជាជីវៈដែលជាគោលដៅដ៏ល្អសម្រាប់បុគ្គលដែលមានមហិច្ឆតាចង់រីកចម្រើន ក្នុងបរិយាកាសការងារ ប្រកបដោយថាមពល និងជវភាព។***

ខ្ញុំជឿជាក់យ៉ាងមុតមាំថា CGCC នឹងបន្តប្រើប្រាស់បច្ចេកវិទ្យាដើម្បីពង្រីកវិសាលភាពរបស់ខ្លួន ដើម្បីទទួលយកការផ្លាស់ប្តូរឌីជីថល និងការសហការជាមួយភាគីពាក់ព័ន្ធ ក្នុងការពង្រីកលទ្ធផលជាវិជ្ជមាន លើការបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា៕

EN With over 15 years of experience in the banking sector, I have gained comprehensive expertise in various IT domains, including database management, core banking administration, and IT operations. My IT career began in 2007 when I joined a bank as a general IT support officer and worked my way up to be Deputy Head of the IT Department. I was also a member of the IT Committee, ensuring the continuous operation of the banking system and implementing IT standards, and policies.

I joined CGCC in May 2021 as the Director of the IT Services Department (ITS) to build an IT system for credit guarantee from scratch and shape the company's IT technical vision and

strategy. I ensure optimal uptime standards across all IT systems by collaborating closely with business and support owners. I am also responsible for IT security, managing projects, ensuring compliance with internal and external standards, and building, and leading a competent team of IT professionals.

I have brought my wealth of experience and expertise to lead the company's IT services. With a focus on technological innovation, compliance, and operational efficiency, I aim to propel CGCC toward its strategic objectives while ensuring a secure and reliable IT infrastructure. For instance, ITS has selected and implemented a number of systems to streamline operations, ensure transparency, and improve efficiency. We encourage information sharing through team communication and collaboration, allowing CGCC employees to work efficiently together. We leverage the cloud-based Microsoft Office 365 environment, which streamlines and secures communication inside the CGCC.

Working at CGCC offers me a multitude of valuable experiences and opportunities for growth. The close-knit environment, fostered by staff and top management, including the CEO, DCEO, and the board, ensures a supportive and collaborative workplace. At CGCC, I am exposed to a visionary company driven by its mission and fueled by a strong sense of purpose. I have opportunities to deal with diverse projects and clients, improving my skills and knowledge. ***For me, the working culture at CGCC promotes innovation, teamwork, and professional development, making it an ideal destination for ambitious individuals seeking to thrive in a dynamic and rewarding work environment.***

I firmly believe that CGCC will continue to leverage technology to expand its reach and embrace digital transformation to strengthen collaboration with stakeholders that will amplify its positive impact on financial inclusion and SME development in Cambodia.

## អបអរសាទរការរៀបអាពាហ៍ពិពាហ៍របស់បុគ្គលិក CGCC | "Celebrating Love and Commitment: CGCC's Staff Ties the Knot"



KH CGCC សូមចូលរួមអបអរសាទរ ចំពោះឱកាសដ៏វិសេសវិសាលបំផុតរបស់ លោកស្រី បួយ គន្ធា អនុប្រធានការិយាល័យប្រតិបត្តិការ ដែលបានរៀបអាពាហ៍ពិពាហ៍ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៣។ គន្ធា គឺជាបុគ្គលិកដ៏ល្អម្នាក់ដែលបានចូលរួមការងារជាមួយ CGCC តាំងពីពាក់កណ្ដាល ឆ្នាំ២០២១ មក។

ថ្នាក់គ្រប់គ្រងនិងបុគ្គលិកទាំងអស់របស់ CGCC សូមចូលរួមសម្ដែងក្ដីត្រេកអរ និងជូនពរយ៉ាងអស់ពីចិត្ត ជូនចំពោះគូស្វាមីភរិយាថ្មី ឱ្យទទួលបាននូវសុភមង្គល វិបុលសុខ ភាពរុងរឿង និងស្នេហាដែលស្រស់បំព្រងជានិច្ចនិរន្តរ៍៕

EN Love is in the air at CGCC as we celebrate the special moments of Mrs. Bouy Kunthea, Deputy Manager of Centralized Operation, who got married on 23 June 2023. Kunthea is one of CGCC's dedicated staff who has joined CGCC since mid of 2021.

CGCC's management and staff would like to extend our heartfelt congratulations and best wishes to the newlyweds for a lifetime of love, happiness, and prosperity.

# វឌ្ឍនភាពការធានាឥណទាន | Credit Guarantee Progress

**ដោយ៖ លោកស្រី ពិន ម៉ានីកា ប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម | By: Ms. Pin Manika, Manager of Marketing and Business Development**

| | |
|---|---|
| គណនីដែលមានការធានា (GA)<br>Guaranteed Account (GA) | **1566** |
| ឥណទានដែលមានការធានា (GL)<br>Guaranteed Loan (GL) | **USD 132.74million Equi.** |
| សន្និធិឥណទានដែលមានការធានា<br>Outstanding Guaranteed Loan | **USD 105.07million Equi.** |
| សន្និធិទំហំការធានាឥណទាន<br>Outstanding Guaranteed Amount | **USD 75.77million Equi.** |
| ភាគរយឥណទានមិនដំណើរការ<br>NPL Ratio of Outstanding Guaranteed Amount | **2.35%** |
| ទំហំសំណងដែលបានបញ្ចេញ<br>Claim Payout | **USD 31,480** |

## គ្រឹះស្ថានហិរញ្ញវត្ថុចូលរួមដែលស្នើសុំការធានាឥណទានបានច្រើនជាងគេ (មេសា-មិថុនា ២០២៣)
## PFIs requesting the most credit guarantees (April-June 2023)

ធនាគារ កាណាឌីយ៉ា 加華銀行 CANADIA BANK

ធនាគារ ស្ថាបនា SATHAPANA BANK

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី LOLC (Cambodia) Plc.

គិតមកដល់ចុងត្រីមាសទី២ នៃឆ្នាំ២០២៣នេះ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) បានផ្តល់ការធានាដល់កម្ចីអាជីវកម្មសរុប ១៥៦៦កម្ចីអាជីវកម្ម ដែលគិតជាទំហំកម្ចីសរុបប្រហាក់ប្រហែល ១៣២,៧៤លានដុល្លារ។ ក្នុងនោះ ១៩៤កម្ចីត្រូវបានផ្តល់ការធានានៅក្នុងឆ្នាំ២០២១ និង ៧៩១កម្ចីត្រូវបានផ្តល់ការធានានៅក្នុងឆ្នាំ២០២២។ កម្ចីទាំង ១៥៦៦នេះបានទទួលការធានាក្រោមគម្រោងធានាឥណទានចំនួន៥គឺ គម្រោងធានាឥណទានដើម្បីស្តារអាជីវកម្ម (BRGS) គម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទាន (CFGS) គម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី (WEGS) គម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទានសម្រាប់វិស័យទេសចរណ៍ (CFGS-TR) និងគម្រោងធានាឥណទានជាកញ្ចប់ (PGS)។ ក្នុងចំណោមទំហំកម្ចីសរុបដែលមានការធានារបស់ CGCC ទាំង ១៣២,៧៤លានដុល្លារ សន្និធិទំហំការធានាឥណទានសរុប គឺមានចំនួន ៧៥,៧៧លានដុល្លារ ដែលនេះគឺជាទំហំហានិភ័យសរុបរបស់ CGCC គិតត្រឹមចុងត្រីមាសទី២ ឆ្នាំ២០២៣។ បើគិតពីអត្រាឥណទានដែលមានការធានាមិនដំណើរការវិញ ក្នុងចំណោមហានិភ័យសរុបរបស់ CGCC ចំនួន ៧៥,៧៧លានដុល្លារនេះ មាន២,៣៥% គឺជាទំហំការធានាឥណទានមិនដំណើរការ (NPL)។

As of the end of the second quarter 2023, the Credit Guarantee Corporation of Cambodia (CGCC) has provided guarantees for a total of 1,566 business loans, with the total loan size of approximately $132.74 million. Of these, 194 guaranteed accounts were approved in 2021 and 791 guaranteed accounts were approved in 2022. These 1,566 loans were guaranteed under all 5 CGCC's guarantee schemes: the Business Recovery Guarantee Scheme (BRGS), the Co-Financing Guarantee Scheme (CFGS), the Women Entrepreneurs Guarantee Scheme (WEGS), and the Co-Financing Guarantee Scheme for Tourism (CFGS-TR) and the Portfolio Guarantee Scheme (PGS). Among CGCC's total loan portfolio of $132.74 million, the total CGCC's risk exposure as of the end of June 2023 is $75.77 million, and among that, 2.35% is the non-performing loans (NPL).

### ១. ការធានាឥណទានប្រចាំខែ |Guarantee Progress by Months

រហូតមកដល់ពាក់កណ្តាលឆ្នាំ២០២៣ ការធានាឥណទានរបស់ CGCC នៅតែបន្តកើនឡើង ដោយ CGCC បានផ្តល់ការធានាឥណទានចំនួន ៥៨១កម្ចី ក្នុងទំហំ ៤០,១លានដុល្លារ ដែលស្មើនឹងជាង ៧៣% នៃការផ្តល់ការធានាឥណទានសរុបក្នុងឆ្នាំ២០២២។ ក្នុងចំណោម ៥៨១កម្ចីនេះ មាន ១០៨កម្ចី ឬស្មើនឹង ១,៩លានដុល្លារ ជាកម្ចីដែលត្រូវបានផ្តល់ការធានាក្រោមគម្រោងធានាឥណទានជាកញ្ចប់ (PGS) ។ CGCC រំពឹងថា ចាប់ពីខែកក្កដា ឆ្នាំ២០២៣នេះទៅ និន្នាការនៃការធានាឥណទានជាកញ្ចប់ នឹងមានការកើនឡើងដោយសារ CGCC គ្រោងដាក់ឱ្យដំណើរការគម្រោងធានាឥណទានជាកញ្ចប់ ចំនួន២ផ្សេងទៀតជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) របស់ CGCC។

As of mid-2023, the momentum of CGCC's credit guarantee continued to grow, with CGCC providing 581 loan guarantees amounting to $40.1 million, representing more than 73% of total credit guarantees in 2022. Of the 581 loans, 108 loans amounting to $1.9 million are guaranteed under the PGS. CGCC expects that from July 2023 onwards, the trend of portfolio guarantees will increase as CGCC plans to launch two more PGSs with participating financial institutions (PFIs).

## Guarantee Progress by Months (2023)




| | 2021 | | 2022 | | | Jan | | Feb | | Mar | | Apr | | May | | June | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | GL | GA | GL | GA | | GL | GA | GL | GA | GL | GA | GL | GA | GL | GA | GL | GA |
| | 21.3mil | 194 | 71.4mil | 791 | PGS | 0 | 0 | .6mil | 31 | .5mil | 29 | .2mil | 10 | .2mil | 10 | .5mil | 28 |
| | | | | | IGS | 5.5mil | 60 | 6.0mil | 79 | 8.3mil | 91 | 6.6mil | 82 | 6.7mil | 88 | 5.2mil | 73 |

*Exchange Rate: USD1 = KHR4,130 *IGS : Individual Guarantee Scheme *PGS : Portfolio Guarantee Scheme *GL : is in USD

## ២. ប្រភេទ និងទំហំកម្ចី |Types and Sizes of Guaranteed Loans

កម្ចីមានកាលកំណត់ គឺជាប្រភេទកម្ចីដែលតែងតែត្រូវបានដាក់ស្នើសុំការធានាច្រើនជាងគេ ដែលក្នុងនោះមាន ១២៤៧កម្ចី ហើយប្រមាណជាង ៧៦%នៃកម្ចីដែលមានការធានាសរុប គឺត្រូវបានស្នើសុំយកមកប្រើប្រាស់ក្នុងគោលបំណងជាទុនបង្វិល ដែលស្មើនឹង ១២០១កម្ចី។ មានតែ ៣៦០កម្ចីប៉ុណ្ណោះ ដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ការវិនិយោគ ឬពង្រីកអាជីវកម្ម។ ក្នុងចំណោមកម្ចីអាជីវកម្មទាំង ១៥៦៦ ៩១,៥%ត្រូវបានស្នើសុំដោយសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម (MSMEs) ហើយមានតែ ១៣៤កម្ចីតែប៉ុណ្ណោះ ដែលជាកម្ចីរបស់សហគ្រាសខ្នាតធំ។ នេះសបញ្ជាក់ឱ្យឃើញថា ទុនបង្វិលនៅតែជាតម្រូវការចម្បងនិងបន្ទាន់សម្រាប់ម្ចាស់អាជីវកម្ម ជាពិសេសអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម។

ទំហំកម្ចីដែលមានការធានាឥណទានជាង ៤៧%មានទំហំតូចជាង ឬស្មើ ៥ម៉ឺនដុល្លារ ដែលនេះជាទំហំកម្ចីសមស្របមួយសម្រាប់អាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម ក្នុងការប្រើប្រាស់ជាទុនបង្វិល ទាំងរយៈពេលវែងនិងរយៈពេលខ្លី។ លើសពីនោះ ក្នុងចំណោមកម្ចីអាជីវកម្មដែលមានការធានាទាំងអស់ប្រមាណ ៦១% (៩៥៩កម្ចី) ជាកម្ចីដែលគ្មានទ្រព្យធានា។

Term loans are the most frequently applied type of guaranteed loans, of which 1,247 are term loans, and more than 76% of the total guaranteed loans are for working capital purposes, equivalent to 1,201 loans. Only 360 loans are used for investment or business expansion purposes. Among the 1566 business loans, 91.5% were applied by micro, small and medium enterprises (MSMEs) and only 134 were applied by large firms. This proves that working capital is still the main and urgent need for business owners, especially MSMEs.

47% of guaranteed loans are loans that are less than or equal to $50,000, a suitable loan size for micro, small and medium businesses to use as working capital, both long and short terms. In addition, about 61% of all guaranteed loans (959 loans) are unsecured.

### Loan Facility




### Loan Purpose




### Loan Size in USD









## ៣. ភូមិសាស្ត្ររបស់កម្ចីដែលមានការធានា | Geographical Coverage (IGS)

CGCC នៅតែបន្តជំរុញការអភិវឌ្ឍរបស់ MSMEs ទៅដល់ទូទាំងប្រទេស ដោយបានពង្រីកវិសាលភាពនៃការធានាឥណទានរបស់ខ្លួន បានគ្រប់ទាំង២៥ខេត្ត/ក្រុង ហើយក៏បានបន្តបង្កើនការធានាឥណទាន នៅក្នុងខេត្ត នីមួយៗជាបន្តបន្ទាប់។ ក្នុងនោះ រាជធានីភ្នំពេញនៅតែមានកម្ចីអាជីវកម្មទទួលបានការធានាច្រើនជាងគេ ដោយកើនឡើងពី ៣៨១កម្ចី ត្រឹមចុងត្រីមាសទី១ ឆ្នាំ២០២៣ មកដល់ ៤៦៤កម្ចី នៅចុងត្រីមាសទី២ ឆ្នាំ២០២៣។ អ្វីដែលគួរឱ្យកត់សម្គាល់ គេក៏សង្កេតឃើញមានការកើនឡើងនូវចំនួនឥណទានដែលមានការធានា នៅក្នុងខេត្ត ដែល CGCC បានធ្វើបេសកកម្មទៅជួបពិភាក្សាជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម និងរៀបចំសិក្ខាសាលាជាមួយម្ចាស់អាជីវកម្មនៅទីនោះ។ ជាក់ស្តែងដូចជានៅក្នុងខេត្តកណ្តាល ព្រៃវែង និងស្វាយរៀង ចំនួនឥណទានមានការធានាសរុបរបស់ខេត្តទាំង៣មានចំនួន ១៨កម្ចីនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ប៉ុន្តែបន្ទាប់ពី CGCC បានចុះធ្វើបេសកកម្មនៅខេត្តទាំង៣នោះ ចំនួនឥណទានមានការធានាសរុបនៅខេត្តទាំង៣បានកើនឡើនចំនួន ៣២កម្ចីក្នុងត្រីមាសទី២ ឆ្នាំ២០២៣។ ចំនួនឥណទានមានការធានាសរុបមិនមានការកើនឡើងពិសេសនោះទេ នៅតាមបណ្តាខេត្តក្រុងផ្សេងៗដែលមាន២១២កម្ចី ក្នុងត្រីមាសទី១ និង ២១១កម្ចីក្នុងត្រីមាសទី២ ឆ្នាំ២០២៣។

CGCC continues to promote the development of MSMEs across the country, extending the scope of its credit guarantee to all 25 provinces/cities, and has continued to increase the number of guaranteed loans in each province. Phnom Penh still has the most guaranteed loans, increasing from 381 loans by the end of the first quarter 2023 to 464 loans by the end of the second quarter 2023. Significantly, there has also been an increase in the number of guaranteed loans in the provinces where CGCC had conducted roadshow and seminar to meet with its PFIs and business owners. For example, in Kandal, Prey Veng and Svay Rieng provinces, the total number of guaranteed loans was 18 in the first quarter of 2023, but after CGCC conducted a roadshow and seminar there, there are additional 32 guaranteed loans in the three provinces in the second quarter of 2023. The total number of guaranteed loans did not change much in other provinces, 212 loans in the first quarter and 211 loans in the second quarter of 2023.




**Q1 (Before Roadshow)**

| Cities \| Provinces | GA |
|---|---|
| Kandal, Prey Veng & Svay Rieng | 18 |
| 22 Cities \| Provinces | 212 |

**Q2 (After Roadshow)**

| Cities \| Provinces | GA |
|---|---|
| Kandal, Prey Veng & Svay Rieng | 32 |
| 22 Cities \| Provinces | 211 |

## ៤. សមាសភាពអ្នកខ្ចី | Gender

ការផ្តល់ការធានាឥណទានជូនសហគ្រិនស្ត្រី និងជំរុញសហគ្រិនស្ត្រីឱ្យទទួលបានហិរញ្ញប្បទានផ្លូវការ គឺជាបេសកកម្មចម្បងមួយដែល CGCC ខិតខំប្រឹងប្រែងបំពេញចាប់តាំងពីការបង្កើត CGCC ដំបូង។ ជាលទ្ធផល កំណើននៃសមាសភាពអ្នកខ្ចីដែលជាស្ត្រីម្ចាស់អាជីវកម្ម មានការកើនឡើងជារៀងរាល់ត្រីមាសចាប់តាំងពីឆ្នាំ២០២១។ គិតមកត្រឹមត្រីមាសទី២ នៃឆ្នាំ២០២៣នេះ សមាសភាពអ្នកខ្ចីដែលជាស្ត្រីម្ចាស់អាជីវកម្មមានចំនួនជិត ៤១% (៦៤០កម្ចី) នៃចំនួនអ្នកខ្ចីសរុប ដែលតួលេខនេះបានកើនឡើងពីត្រឹម២៣% ក្នុងឆ្នាំ២០២១ មកដល់ ៣៥% ត្រឹមចុងឆ្នាំ២០២២។

Providing credit guarantees to women entrepreneurs and encouraging women entrepreneurs to receive formal financing is one of the main missions that CGCC has been striving to fulfill since its inception. As a result, the composition of female business owners keeps increasing quarterly since 2021. As of the second quarter of 2023, the percentage of female business owners accounted for nearly 41% (640 loans) of the total number of borrowers, an increase from 23% in 2021 and from 35% by the end of 2022.



# កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ | Cooperation and Partnership

## ជំនួបពិភាក្សាការងារជាមួយ UN Women និង United Nations Environment Programme (UNEP) អំពីលទ្ធភាពនៃកិច្ចសហប្រតិបត្តិការលើគម្រោង “EmPower-II: Women for Climate-Resilient Societies”

## Meeting with UN Women and United Nations Environment Programme (UNEP) to Discuss about the Possible Collaboration on a Project Called “EmPower-II: Women for Climate-Resilient Societies”

នៅរសៀលថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ CGCC ដឹកនាំដោយលោក Wong Keet Loong បានជួបពិភាក្សាការងារជាមួយ UN Women និង United Nations Environment Programme (UNEP) អំពីលទ្ធភាពនៃកិច្ចសហប្រតិបត្តិការលើគម្រោង “EmPower-II: Women for Climate-Resilient Societies”។

Read more in English: https://www.cgcc.com.kh/en/article/11463/



## ពិធីចុះហត្ថលេខាជាផ្លូវការលើអនុស្សរណៈនៃការយោគយល់គ្នា រវាងសាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងសភាពាណិជ្ជកម្មកម្ពុជា (CCC)

## Signing Ceremony on the Memorandum of Understanding (MoU) Between Credit Guarantee Corporation of Cambodia (CGCC) and Cambodia Chamber of Commerce (CCC)

សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងសភាពាណិជ្ជកម្មកម្ពុជា (CCC) បានប្រកាសភាពជាដៃគូយុទ្ធសាស្ត្រ តាមរយៈពិធីចុះហត្ថលេខាជាផ្លូវការលើអនុស្សរណៈនៃការយោគយល់គ្នា នៅទីស្នាក់ការកណ្ដាលសភាពាណិជ្ជកម្មកម្ពុជា ក្នុងគោលបំណងលើកស្ទួយដល់លទ្ធភាពទទួលបានកម្ចីដែលមានការធានា សម្រាប់ការអភិវឌ្ឍសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម (MSMEs) នៅកម្ពុជា។ កិច្ចសហប្រតិបត្តិការនេះនឹងផ្ដល់ការគាំទ្រ ជាពិសេសដល់សមាជិកសមាជិកាសភាពាណិជ្ជកម្មកម្ពុជា សម្រាប់ការបង្កើនលទ្ធភាពទទួលហិរញ្ញប្បទាន ឆ្លើយតបទៅនឹងបញ្ហាខ្វះទ្រព្យធានា និងជាពិសេសចូលរួមលើកស្ទួយចំណេះដឹងហិរញ្ញវត្ថុ រួមជាមួយនឹងការធានាឥណទាន ទៅកាន់សមាជិកសមាជិការបស់សភាពាណិជ្ជកម្មកម្ពុជានៅទូទាំងប្រទេស។

ភាពជាដៃគូរវាង CGCC និង CCC នេះបង្ហាញពីការប្ដេជ្ញាចិត្តរួមគ្នាក្នុងការលើកកម្ពស់ការអភិវឌ្ឍកំណើនសេដ្ឋកិច្ច នៅកម្ពុជា។ តាមរយៈស្មារតីរួមគ្នានេះ ស្ថាប័នទាំងពីរនឹងសម្រួលដល់ក្រុមហ៊ុន/អាជីវកម្ម ដោយចូលរួមដោះស្រាយនូវបញ្ហាប្រឈមផ្នែកហិរញ្ញប្បទាន និងបើកបង្ហាញពីសក្ដានុពលរបស់ពួកគេដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងប្រទេសផងដែរ៕

Read more in English: https://www.cgcc.com.kh/en/article/11487/






## ជំនួបសម្តែងការគួរសម និងពិភាក្សាលើស្ថានភាពនៃទីផ្សារឥណទាននៅកម្ពុជា របស់ CGCC ជាមួយធនាគារជាតិនៃកម្ពុជា

### Courtesy Visit by CGCC to NBC to Discuss on the Current Situation of the Credit Market in Cambodia

លោក Wong Keet Loong អគ្គនាយក CGCC បានដឹកនាំសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម រ័ត្ន សុវណ្ណនរៈ ឧបការីទេសាភិបាល និងជាអគ្គនាយកត្រួតពិនិត្យ NBC រួមជាមួយនឹងសហការី។

លោកអគ្គនាយក CGCC បានសម្តែងក្តីសោមនស្ស ចំពោះការស្វាគមន៍ដ៏កក់ក្តៅរបស់ឯកឧត្តមឧបការីទេសាភិបាល និងបានជម្រាបជូន អំពីវឌ្ឍនភាពការងាររបស់ CGCC ក្នុងការផ្តល់ការធានាឥណទាននារយៈកាលកន្លងមក ក៏ដូចជាផែនការយុទ្ធសាស្ត្ររបស់ CGCC ដែលចាំបាច់ត្រូវការការសហការ និងការគាំទ្រពី NBC។



ជាកិច្ចឆ្លើយតប ឯកឧត្តមឧបការីទេសាភិបាល បានកោតសរសើរចំពោះវឌ្ឍនភាពការងាររបស់ CGCC និងបានបង្ហាញការគាំទ្រដល់បេសកកម្មរបស់ CGCC ក្នុងការផ្តល់ការធានាឥណទានលើកម្ចី ដែលបញ្ចេញដោយធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដល់ក្រុមហ៊ុនអាជីវកម្ម ដែលខ្វះទ្រព្យធានា ជាពិសេសសហគ្រាសធុនតូច និងមធ្យម ដែលជាឆ្អឹងខ្នងដ៏សំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់សហគ្រាសទាំងនោះ។

អង្គប្រជុំក៏បានផ្លាស់ប្តូរយោបល់គ្នាអំពីវឌ្ឍនភាពសំខាន់ៗក្នុងវិស័យធនាគារ និងក្របខ័ណ្ឌបទប្បញ្ញត្តិថ្មីៗរបស់ NBC ព្រមទាំងអនុសាសន៍នានា ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ ឈរលើស្មារតីរួម គឺបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងពង្រីកលទ្ធភាពទទួលបានហិរញ្ញប្បទាន ប្រកបដោយប្រសិទ្ធភាព៕

Read more in English: https://www.cgcc.com.kh/en/article/11703/

## កិច្ចពិភាក្សាស្វែងយល់ និងពង្រឹងកិច្ចសហការលើការធានាឥណទានរវាង CGCC និងគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម សាខាខេត្តកំពង់ចាម ខេត្តកំពង់ធំ និង ខេត្តព្រះវិហារ

### CGCC Visits PFIs Provincial Branches in Kompong Cham, Kompong Thom and Preah Vihear, to Enhance Collaboration on the Credit Guarantee




កាលពីថ្ងៃទី០៥ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) ដឹកនាំដោយ លោក ណូ លីដា អគ្គនាយករង បានជួបពិភាក្សាស្វែងយល់អំពីការអនុវត្តគម្រោងធានាឥណទាន និងផ្សព្វផ្សាយបន្ថែមអំពីគម្រោងធានាឥណទានរបស់ CGCC ដោយផ្ទាល់ជាមួយថ្នាក់ដឹកនាំ និងបុគ្គលិករបស់សាខានៃគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) មួយចំនួនរបស់ CGCC រួមមាន៖

- នៅខេត្តកំពង់ចាម រួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន ធនាគារ Maybank និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK
- នៅខេត្តកំពង់ធំ រួមមាន ធនាគារស្ថាបនា ធនាគារ ABA ធនាគារកាណាឌីយ៉ា និង ធនាគារព្រីនស៍
- នៅខេត្តព្រះវិហារ រួមមាន ធនាគារព្រីនស៍ ធនាគារអេស៊ីលីដា ធនាគារ ABA និងធនាគារស្ថាបនា។




កិច្ចពិភាក្សាជាមួយ PFIs របស់ CGCC នៅខេត្តទាំងបី គឺជាឱកាសមួយដ៏ពិសេសសម្រាប់ទាំង CGCC និង PFIs ស្វែងយល់អំពីភាពចាំបាច់នៃការធានាឥណទាន និងឱកាសដែល PFIs អាចបង្កើនការផ្តល់កម្ចីជូនទៅដល់ក្រុមហ៊ុនអាជីវកម្ម ដែលមានតម្រូវការកម្ចីតែខ្វះទ្រព្យធានា៕

Read more in English: https://www.cgcc.com.kh/en/article/11987/

*បន្តនៅទំព័របន្ទាប់*







## ការចុះអនុស្សរណៈនៃការយោគយល់គ្នា រវាង សាជីវកម្មធានាឥណទានកម្ពុជា ធនាគារ មេយប៊ែង ខេមបូឌា BNI Super និងសមាគមសហគ្រិនស្រ្តីកម្ពុជា

### MoU Signing between CGCC, Maybank Cambodia, BNI-Super, and CWEA to Elevate SME Capacity and Capability Building

កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ សាជីវកម្មធានាឥណទានកម្ពុជា ធនាគារ មេយប៊ែង ខេមបូឌា BNI Super និងសមាគមសហគ្រិនស្រ្តីកម្ពុជា បានចុះ MOU ដើម្បីកសាងសមត្ថភាព និងជំនាញរបស់សហគ្រាសធុនតូច និងមធ្យម។ MOU នេះនឹងត្រួសត្រាយផ្លូវដល់ការពង្រីកបណ្តាញទំនាក់ទំនង ក៏ដូចជាគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម តាមរយៈវគ្គបណ្តុះបណ្តាល វេទិកាទំនាក់ទំនងគ្នា និងការចែករំលែកចំណេះដឹងទាំងផ្នែកទ្រឹស្តី ការអនុវត្ត និងបច្ចេកទេសនានា។







MOU នេះ ត្រូវបានរៀបចំឡើងក្រោមសក្ខីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ សុក ស៊ីផាណា នាយកនៃការិយាល័យមេធាវី សុក ស៊ីផាណា និងសហការី និងជាប្រធានក្រុមប្រឹក្សានៃវិទ្យាស្ថាន Asian Vision Institute និងត្រូវបានចុះហត្ថលេខាដោយ លោក Wong Keet Loong អគ្គនាយក CGCC លោក រ័ត្ន សោភ័ណ នាយកប្រតិបត្តិ និងនាយកប្រចាំប្រទេសរបស់ធនាគារមេយប៊ែង លោកជំទាវ ជា រដ្ឋា អនុប្រធានសមាគមសហគ្រិនស្រ្តីកម្ពុជា និង លោក គ្រុយ ឬទ្ធី ប្រធាន BNI Super៕

Read more in English: https://www.cgcc.com.kh/kh/article/11950/

## ជំនួបជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា ពិភាក្សាលើលទ្ធភាពសហការ ដើម្បីគាំទ្រដល់វិស័យស្រូវអង្ករកម្ពុជា

### Meeting with the Cambodian Rice Federation to Discuss the Possibility of Cooperation to Support the Cambodian Rice Sector




នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ នៅទីស្នាក់ការនៃលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា លោក Wong Keet Loong អគ្គនាយក CGCC និងសហការីចំនួនពីររូបទៀត បានចូលជួបប្រជុំជាមួយ ឧកញ៉ា ចាន់ សុឃាំង ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីពិភាក្សាពីលទ្ធភាពនៃការសហការ ដើម្បីលើកស្ទួយដល់វិស័យស្រូវអង្ករកម្ពុជា។ នៅក្នុងកិច្ចប្រជុំនេះ ភាគីទាំងពីរបានចែករំលែកអំពីវិស័យស្រូវអង្ករ ក៏ដូចជាពិភាក្សាអំពីគម្រោងនៃការផ្តល់ការធានាឥណទានលើហិរញ្ញប្បទានមកលើវិស័យស្រូវអង្ករកម្ពុជា៕

Read more in English: https://www.cgcc.com.kh/en/article/12499/

# ការផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីការធានាធានាឥណទាន | Raising Awareness of Credit Guarantee

## សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី “កម្ចីដែលមានការធានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម” នៅខេត្តកំពង់ធំ

### Dissemination Seminar on “Guaranteed Loans to Support the Development of Small and Medium Enterprises” in Kompong Thom Province





នាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងសភាពាណិជ្ជកម្មកម្ពុជា (CCC) បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី “កម្ចីដែលមានការធានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម” នៅឯខេត្តកំពង់ធំ ក្រោមកិច្ចសហការរបស់ សភាពាណិជ្ជកម្មមណ្ឌលខេត្តកំពង់ធំ ព្រះវិហារ និងការចូលរួមពីថ្នាក់ដឹកនាំ និងបុគ្គលិកនៃគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) មួយចំនួន និងបណ្តាសហគ្រិនដែលជាម្ចាស់អាជីវកម្មខ្នាតតូច និងមធ្យម នៅក្នុងខេត្តកំពង់ធំ និងបណ្តាខេត្តផ្សេងៗទៀត ជាង១០០នាក់។ សិក្ខាសាលាផ្សព្វផ្សាយនេះ ទទួលបានការអញ្ជើញចូលរួមជាអធិបតីដោយ លោកឧកញ៉ា តាន់ មុន្នី អនុប្រធានសភាពាណិជ្ជកម្មមណ្ឌលខេត្តកំពង់ធំ - ព្រះវិហារ និង លោក ណូ លីដា អគ្គនាយករង CGCC លោក ជួន គឹមយាន់ នាយកប្រតិបត្តិ សហភាពសហគមន៍កសិកម្មកំពង់ធំតេជៈមានជ័យ ព្រមទាំងការធ្វើបទបង្ហាញរបស់អ្នកតំណាងមកពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ និង ធនាគារកាណាឌីយ៉ាផងដែរ។

តាមរយៈសិក្ខាសាលាផ្សព្វផ្សាយនេះ សហគ្រិននៃអាជីវកម្មខ្នាតតូច និងមធ្យម បានជ្រាបអំពីព័ត៌មាននៃអត្ថប្រយោជន៍របស់កម្ចីដែលមានការធានា និងការរៀបចំខ្លួនដើម្បីទទួលបានកម្ចីដែលមានការធានា ពីគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមរបស់ CGCC ឆ្លើយតបទៅនឹងបញ្ហាខ្វះទ្រព្យធានាពេលស្នើសុំកម្ចី សម្រាប់ពង្រីក និងស្តារអាជីវកម្មរបស់ខ្លួនទៀតផង៕

Read more in English: https://www.cgcc.com.kh/kh/article/11950/

## កិច្ចពិភាក្សាស្តីពី “ស្ថានភាពសេដ្ឋកិច្ចនៅប្រទេសកម្ពុជា និងការប្រឈម និងឱកាសនានារបស់សហគ្រាសខ្នាតតូច និងមធ្យម”

### Discussion on “Cambodia Economic Outlook”




នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ លោក ណូ លីដា អគ្គនាយករង CGCC បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស នៅក្នុងកិច្ចពិភាក្សាស្តីពី “ស្ថានភាពសេដ្ឋកិច្ចនៅប្រទេសកម្ពុជា និងការប្រឈម និងឱកាសនានារបស់សហគ្រាសខ្នាតតូច និងមធ្យម” ជាមួយវាគ្មិនកិត្តិយស ៣រូបទៀតគឺ ឯកឧត្តមបណ្ឌិតសភាចារ្យ សុក ស៊ីផាណា នាយកនៃការិយាល័យមេធាវី សុក ស៊ីផាណា និងជាប្រធានក្រុមប្រឹក្សានៃវិទ្យាស្ថាន Asian Vision Institute លោកជំទាវ ជា រដ្ឋា អនុប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា និងលោក រ័ត្ន សោភ័ណ នាយកប្រតិបត្តិធនាគារ មេយប៊ែង។

លោក ណូ លីដា បានបង្ហាញសុទិដ្ឋិនិយមអំពីទស្សនវិស័យនៃសេដ្ឋកិច្ចកម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងវិញនូវអត្រាកំណើនសេដ្ឋកិច្ច បន្ទាប់ពីវិបត្តិជម្ងឺកូវីដ-១៩ ក្រោមកត្តាអំណោយផលនៃស្ថិរភាពសេដ្ឋកិច្ច នយោបាយ និងកំណែទម្រង់សាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ យ៉ាងណាក៏ដោយ បញ្ហាប្រឈមនៅតែមាន ជាពិសេសការកើនឡើងនៃអតិផរណា និងអត្រាការប្រាក់ ព្រមទាំងឥទ្ធិពលជាអវិជ្ជមានផ្សេងទៀតពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ ក្នុងបរិបទនេះ CGCC នឹងបន្តបេសកកម្មរបស់ខ្លួនក្នុងការជួយសម្រួលដល់ម្ចាស់អាជីវកម្ម ឱ្យទទួលបានកម្ចីចាំបាច់នានាសម្រាប់ទ្រទ្រង់ និងពង្រីកអាជីវកម្ម ឆ្លើយតបនឹងបញ្ហាប្រឈមលើទ្រព្យធានា និងបង្កើនទំនុកចិត្តដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្រោមការធានាឥណទានរបស់រាជរដ្ឋាភិបាលតាមរយៈ CGCC។ លោក ណូ លីដា ក៏បានលើកទឹកចិត្តដល់សហគ្រិន ឱ្យចាប់យកនូវកាលានុវត្តភាព ក្នុងការពង្រីកសមត្ថភាពក្នុងការគ្រប់គ្រងនិងអភិវឌ្ឍអាជីវកម្ម ដើម្បីបង្កើនភាពប្រកួតប្រជែងក្នុងស្រុក និងអន្តរជាតិ ខណៈដែលសេដ្ឋកិច្ចកម្ពុជាកំពុងតែបោះជំហានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាពេលដ៏ខ្លីខាងមុខ៕

Read more in English: https://www.cgcc.com.kh/en/article/11941/

## កិច្ចប្រជុំសំខាន់ៗ | Notable Meetings

### កិច្ចប្រជុំបុគ្គលិក CGCC ប្រចាំឆ្នាំ២០២៣ ស្ដីអំពីវឌ្ឍនភាព និងផែនការការងារសម្រាប់ឆ្នាំថ្មី
### CGCC Town Hall Meeting 2023 on “Milestones and Strategic Plan”



នាថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ CGCC បានរៀបចំកិច្ចប្រជុំបុគ្គលិកប្រចាំឆ្នាំ២០២៣ ដើម្បីពិនិត្យមើលវឌ្ឍនភាពការងារប្រចាំឆ្នាំ២០២២ និងត្រីមាសទី១ ឆ្នាំ២០២៣ និងផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋាននីមួយៗសម្រាប់ឆ្នាំ២០២៣។ កិច្ចប្រជុំប្រចាំឆ្នាំនេះ មានការចូលរួមពីគ្រប់បុគ្គលិកគ្រប់ជាន់ថ្នាក់របស់ CGCC។ កិច្ចប្រជុំនេះ មិនមែនត្រឹមតែជាវេទិកាដើម្បីធ្វើបទបង្ហាញពីនាយកដ្ឋានពាក់ព័ន្ធទាំងអស់នោះទេ តែជាឱកាសក្នុងការជួបពិភាក្សាក៏ដូចជាទទួលអនុសាសន៍ក្នុងការអនុវត្តការងារ ដើម្បីចូលរួមចំណែកសម្រេចចក្ខុវិស័យរួមរបស់ CGCC ក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា។

ក្នុងរយៈពេលជាង២ឆ្នាំកន្លងទៅ CGCC បានរីកចម្រើនជាលំដាប់ ក្រោមការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាអាណាព្យាបាល និងការដឹកនាំពីថ្នាក់គ្រប់គ្រង ដែលមានបទពិសោធន៍នៅក្នុងវិស័យសេដ្ឋកិច្ច ធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងការចូលរួមដ៏សកម្មពីបុគ្គលិកទាំងអស់ ដែលបានបំពេញការងារ ប្រកបដោយស្មារតីសាមគ្គីភាព និងការទទួលខុសត្រូវ។

Read more in English: https://www.cgcc.com.kh/en/article/11363/

### សិក្ខាសាលាស្ដីពី Strengthening Responsible Inclusive Finance in Cambodia
### Workshop on Strengthening Responsible Inclusive Finance in Cambodia

កាលពីថ្ងៃទី២០ ដល់ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ លោក អាំង សុវណ្ណារ៉ា ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងអនុលោមភាព តំណាងឱ្យ CGCC បានចូលរួមសិក្ខាសាលាស្ដីពី Strengthening Responsible Inclusive Finance in Cambodia ដែលរៀបចំឡើងដោយ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និង CERISE+SPTF។ សិក្ខាសាលានេះមានគោលបំណងប្រមូលផ្ដុំភាគីពាក់ព័ន្ធ រួមមាន ធនាជាតិនៃកម្ពុជា (NBC), សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA), សមាគមធនាគារនៅកម្ពុជា (ABC) និងសមាគម Fintech និងស្ថាប័នគាំទ្រលើផ្នែកហិរញ្ញវត្ថុដូចជា សាជីវកម្មធានាឥណទានកម្ពុជា (CGCC), ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) (CBC), និង វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (IBF) ដើម្បីពិភាក្សា និងស្វែងរកវិធីកែលម្អការរួមបញ្ចូលផ្នែកហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវនៅកម្ពុជា។ CGCC ក្នុងនាមជាអ្នកផ្ដល់ការធានាឥណទាន អាចជួយកែលម្អលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យម ក៏ដូចជារួមចំណែកក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ ប្រកបដោយការទទួលខុសត្រូវនៅក្នុងប្រទេសកម្ពុជា។




Read more in English: https://www.cgcc.com.kh/en/article/11473/

## កិច្ចប្រជុំក្រុមប្រឹក្សាភិបាល CGCC អាណត្តិទី១ លើកទី១៤

### 14th Board of Directors Meeting of Credit Guarantee Corporation of Cambodia (CGCC)



នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ២:០០នាទីរសៀល CGCC បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាណត្តិទី១ លើកទី១៤ នៅសណ្ឋាគាររ៉ូសវូដ ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ CGCC ដោយមានការចូលរួមពី សមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ។

របៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៤ នេះ រួមមាន៖

(១) របាយការណ៍ស្តីពីវឌ្ឍនភាពការងាររបស់ CGCC

(២) របាយការណ៍សវនកម្មផ្ទៃក្នុងលើប្រតិបត្តិការធានាឥណទាន

(៣) ការធានាឥណទានជាកញ្ចប់ជាមួយធនាគារណាឌីយ៉ា ធនាគារស្ថាបនា និងធនាគារព្រីនស៍

(៤) ការបង្កើតគណៈកម្មាធិការវិនិយោគរបស់ក្រុមប្រឹក្សាភិបាល

(៥) គោលនយោបាយវិស្សលប្ដូវឹង

(៦) ផ្សេងៗ៕

Read more in English: https://www.cgcc.com.kh/en/article/12463/



# សេចក្តីប្រកាសព័ត៌មាន ប្រកាសស្តីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ របស់ធនាគារជាតិនៃកម្ពុជា | Press Release – Prakas on Credit Risk for Capital Adequacy Ratios in Deposit-Taking Banks and Financial Institutions of National Bank of Cambodia




KH សាជីវកម្មធានាឥណទានកម្ពុជា (CGCC) មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមរបស់ CGCC ឱ្យបានជ្រាបថា នាថ្ងៃទី២៩ មិថុនា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យអនុវត្ត *"ប្រកាសស្តីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុន របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ"*។ តាមរយៈសេចក្តីប្រកាសព័ត៌មានរបស់ធនាគារជាតិនៃកម្ពុជា នាថ្ងៃដដែល ប្រកាសស្តីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនេះ មានគោលបំណងដាក់ចេញនូវវិធានការ នៃការថ្លឹងហានិភ័យឥណទានយ៉ាងទូលំទូលាយ ដែលការថ្លឹងនេះមានកម្រិតខុសៗគ្នាផ្អែកលើប្រភេទឥណទានអ្នកខ្ចី ឬសមភាគី និងឆ្លុះបង្ហាញពីកម្រិតហានិភ័យដែលគ្រឹះស្ថានអាចប្រឈមជាក់ស្តែង សំដៅពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យ។

សេចក្តីប្រកាសព័ត៌មាន របស់ធនាគារជាតិនៃកម្ពុជា ក៏បានលើកឡើងផងដែរ ពីការដាក់វិធានការប្រុងប្រយ័ត្ន និងថ្លឹងថ្លែង និងគិតគូរយ៉ាងម៉ត់ចត់ដល់ការជំរុញការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ចជាតិ ព្រមទាំងចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការជំរុញការអនុវត្តគោលនយោបាយពាក់ព័ន្ធ ដែលក្នុងនោះក៏មាន ការយកចិត្តទុកដាក់ពិសេសចំពោះ *"ការគាំទ្រដល់យន្តការធានាឥណទានដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដូចជា សាជីវកម្មធានាឥណទានកម្ពុជា (CGCC) ដោយការថ្លឹងហានិភ័យសូន្យភាគរយចំពោះចំណែកឥណទានដែលត្រូវបានធានា ដើម្បីសម្រួលឱ្យសហគ្រាសធុនមីក្រូ តូច និងមធ្យម ទទួលបានប្រភពទុនកាន់តែច្រើនជាងមុន"*។

គួរបញ្ជាក់ផងដែរថា សាជីវកម្មធានាឥណទានកម្ពុជា គឺជាក្រុមហ៊ុនធានាឥណទានមុនដំបូងបង្អស់នៅកម្ពុជា ដែលត្រូវបានសម្រេចបង្កើតឡើងដោយ *សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី* ជាសហគ្រាសសាធារណៈ ក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បេសកកម្មចម្បងរបស់សាជីវកម្មធានាឥណទានកម្ពុជា គឺផ្តល់ការធានាឥណទានលើកម្ចី ដែលផ្តល់ឱ្យអាជីវកម្ម ដើម្បីចែករំលែកហានិភ័យជាមួយស្ថាប័នផ្តល់កម្ចី និងបង្កើនបរិយាបន្នហិរញ្ញវត្ថុ៕

EN Credit Guarantee Corporation of Cambodia (CGCC) is pleased to inform the Participating Financial Institutions (PFIs) that on 29th June 2023 the National Bank of Cambodia (NBC) announced the implementation of *"Prakas on Credit Risk for Capital Adequacy Ratios in Deposit-Taking Banks and Financial Institutions".* In the press release issued on the same day about this Prakas on Credit Risk for Capital Adequacy Ratios in Deposit-Taking Banks and Financial Institutions, NBC stated the purpose of this Prakas is to develop a comprehensive credit risk weight, which varies according to the type of credit, borrowers, or counterparties and reflect the level of risk that the institution may actually face in order to strengthen the effectiveness of risk management.

The press release of NBC also mentioned the implementation of prudent and well-balanced measures and careful consideration to promoting the development of the banking and financial sector and national economic growth, as well as to support the Royal Government of Cambodia in implementing relevant policies, including special attention to *"Support credit guarantee mechanisms established by the Royal Government of Cambodia, such as the Credit Guarantee Corporation of Cambodia (CGCC), with a zero percent risk weight on the part of the exposure that is guaranteed in order to facilitate Micro, Small and Medium Enterprises in access to more sources of fund".*

CGCC is the first-ever credit guarantee corporation in Cambodia, established by the decision of *Samdech Akka Moha Sena Padei Techo Hun Sen, Prime Minister* as a state-owned enterprise under the technical and financial guidance of the Ministry of Economy and Finance. CGCC's main mission is to provide credit guarantees to lenders on loans made to businesses based on international standards to share the risk with lenders and to improve financial inclusion.

## អត្ថបទស្វែងយល់ពីការធានាឥណទាន | Article on Understanding Credit Guarantee

### ស្វែងយល់ពីហានិភ័យការជ្រើសរើស និងហានិភ័យចិត្តសាស្ត្រ

ដោយ៖ លោក ណូ លីដា អគ្គនាយករង

KH ហានិភ័យការជ្រើសរើស (Adverse Selection) និងហានិភ័យចិត្តសាស្ត្រ (Moral Hazard) កើតឡើងដោយសារអសមភាពនៃព័ត៌មាន (Asymmetry Information) ដែលអាចនាំឱ្យមានភាពបរាជ័យនៃទីផ្សារ។ អសមភាពនៃព័ត៌មាន គឺជាស្ថានភាពដែលភាគីនានា ក្នុងប្រតិបត្តិការណាមួយ មិនមានព័ត៌មានស្មើគ្នា ដើម្បីអនុវត្តប្រតិបត្តិការនោះដោយយុត្តិធម៌ និងស្មើភាពគ្នា។ ឧទាហរណ៍ ក្នុងការទិញឡានមួយទឹក អ្នកទិញ មិនដឹងអំពីចំណុចខ្វះខាតនៃឡាននោះ គ្រប់ជ្រុងជ្រោយ ដូចម្ចាស់ឡានដែលជាអ្នកលក់នោះទេ។ ដូច្នេះ អ្នកលក់អាចកំណត់តម្លៃបានត្រឹមត្រូវជាង ខណៈអ្នកទិញមិនមានព័ត៌មានស្មើគ្នា ដើម្បីចរចារតម្លៃឱ្យមកនៅកម្រិតមួយ ដែលឆ្លុះបញ្ចាំងពីស្ថានភាពពិតប្រាកដរបស់ឡាននោះទេ។ ក្នុងស្ថានភាពនេះ អសមភាពនៃព័ត៌មានអាចបណ្តាលឱ្យមានភាពបរាជ័យនៃទីផ្សារ ដោយសារមិនមានការទិញ-លក់ ព្រោះអ្នកទិញគិតថា គ្រប់តម្លៃឡានដែលអ្នកលក់ព្រមលក់ នឹងផ្តល់ផលប្រយោជន៍ដល់អ្នកលក់ច្រើនជាង។ អសមភាពនៃព័ត៌មាន គឺជាទ្រឹស្តីដែលត្រូវបានបង្កើតដោយសេដ្ឋវិទូ ដែលបានឈ្នះរង្វាន់ណូបែល George Akerlof ក្នុងឆ្នាំ១៩៧០។




អសមភាពនៃព័ត៌មាន អាចកើតឡើងនៅក្នុងប្រតិបត្តិការច្រើនប្រភេទ។ នៅក្នុងប្រតិបត្តិការធនាគារ អ្នកខ្ចីជាទូទៅមានព័ត៌មានច្បាស់លាស់អំពីលទ្ធភាពសងរបស់ខ្លួន ជាងធនាគារដែលផ្តល់កម្ចី ដែលធ្វើឱ្យមានការលំបាកសម្រាប់ធនាគារក្នុងការកំណត់តម្លៃកម្ចី (អត្រាការប្រាក់) ដែលឆ្លុះបញ្ចាំងពិតប្រាកដពីស្ថានភាពរបស់អ្នកខ្ចី។ ដោយឡែក នៅក្នុងប្រតិបត្តិការធានាឥណទាន អសមភាពនៃព័ត៌មាន កើតឡើងនៅពេលស្ថាប័នផ្តល់កម្ចី ដែលស្នើសុំការធានាលើកម្ចីដឹងព័ត៌មានអំពីកម្ចី និងអ្នកខ្ចី ច្រើនជាងស្ថាប័នដែលផ្តល់ការធានាលើកម្ចី។ អសមភាពនៃព័ត៌មាន អាចបណ្តាលឱ្យមានបញ្ហាពីរគឺ៖ ហានិភ័យការជ្រើសរើស និងហានិភ័យចិត្តសាស្ត្រ។

នៅពេលមានអសមភាពនៃព័ត៌មាន ធនាគារមិនអាចបែងចែករវាងអ្នកខ្ចីល្អ និងអ្នកខ្ចីមិនល្អនោះទេ។ ដោយសារប្រឈមនឹងហានិភ័យនេះ ធនាគារអាចនឹងកំណត់ការប្រាក់មួយ ដែលខ្ពស់ពេកសម្រាប់អ្នកខ្ចីល្អ។ អ្នកខ្ចីល្អនឹងចាកចេញពីទីផ្សារ នៅសល់តែអ្នកខ្ចីមិនល្អដែលស្វែងរកស្នើសុំកម្ចី។ ករណីនេះ ហៅថាហានិភ័យការជ្រើសរើស។ ដូច្នេះ វិធីសាស្ត្រមួយដើម្បីបង្កើនប្រសិទ្ធភាពទីផ្សារឥណទាន គឺបង្រួមភាពខុសគ្នានៃការដឹងព័ត៌មានពីគ្នា រវាងអ្នកខ្ចី និងអ្នកផ្តល់កម្ចី។ ហេតុនេះហើយ ទើបធនាគារតែងតែទាមទារព័ត៌មានទាំងអស់ពីអ្នកខ្ចីតាមដែលអាចធ្វើបាន មុនពេលផ្តល់កម្ចី ដើម្បីចៀសវាងហានិភ័យការជ្រើសរើស។ ព័ត៌មានគ្រប់គ្រាន់ ជឿទុកចិត្តបាន និងទាន់ពេលវេលាអំពីអ្នកខ្ចី អាចជួយធនាគារ ឱ្យដឹងពីស្ថានភាពពិតប្រាកដរបស់អ្នកខ្ចី ដើម្បីកំណត់លក្ខខណ្ឌកម្ចី ដែលផ្តល់អត្ថប្រយោជន៍ឱ្យភាគីទាំងពីរ។ ដូចគ្នាដែរ ហានិភ័យការជ្រើសរើស នៅក្នុងប្រតិបត្តិការធានាឥណទាន គឺជាហានិភ័យដែលស្ថាប័នផ្តល់កម្ចី ដែលដឹងព័ត៌មានពីអ្នកខ្ចី ជ្រើសយកតែកម្ចីមិនល្អសម្រាប់ស្នើសុំការធានាពីស្ថាប័នផ្តល់ការធានាឥណទាន។

លើសពីនេះ អសមភាពនៃព័ត៌មានក៏អាបណ្តាលឱ្យមានហានិភ័យចិត្តសាស្ត្រផងដែរ ដែលកើតឡើងនៅពេលភាគីម្ខាងនៃកិច្ចសន្យាធ្វើសកម្មភាពដោយមិនយកចិត្តទុកដាក់ ដែលបណ្តាលឱ្យភាគីម្ខាងទៀតប្រឈមនឹងការខាតបង់។ នៅក្នុងប្រតិបត្តិការធានាឥណទាន ហានិភ័យចិត្តសាស្ត្រ គឺនៅពេលស្ថាប័នផ្តល់កម្ចី ដែលមានកម្ចីធានាដោយស្ថាប័នធានាឥណទាន មិនយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងកម្ចីដែលមានការធានា ដោយគិតថាការបាត់បង់នៃកម្ចីដែលមានការធានានោះត្រូវបានរ៉ាប់រងភាគច្រើន ដោយស្ថាប័នធានាឥណទាន។ ដូចគ្នាដែរ ហានិភ័យចិត្តសាស្ត្រក៏អាចកើតឡើងដោយសារអ្នកខ្ចីកម្ចីដែលមានការធានាមិនមានឆន្ទៈក្នុងការទូទាត់សង ដោយគិតថាកម្ចីនោះត្រូវបានធានាដោយភាគីទីបី។

ហានិភ័យចិត្តសាស្ត្រ និងហានិភ័យនៃការជ្រើសរើស គឺជាបញ្ហាធ្ងន់ធ្ងរដែលអាចបណ្តាលឱ្យគម្រោងធានាឥណទានទទួលបរាជ័យប្រសិនបើមិនគ្រប់គ្រងហានិភ័យនេះឱ្យបានត្រឹមត្រូវ និងប្រយ័ត្នប្រយែង។ CGCC ដែលជាស្ថាប័នធានាឥណទានប្រឈមមុខខ្ពស់នឹងបញ្ហានេះ។ ដូច្នេះ ដើម្បីកាត់បន្ថយហានិភ័យនេះ CGCC បានប្រកាន់ភ្ជាប់នូវគោលនយោបាយសំខាន់ៗ ដូចខាងក្រោម៖

- តម្រូវឱ្យ PFIs អនុម័តកម្ចីជាមុន ដោយផ្អែកលើស្តង់ដារនៃការវាយតម្លៃឥណទាន មុននឹងស្នើសុំការធានាឥណទានពី CGCC ដើម្បីកាត់បន្ថយហានិភ័យជ្រើសរើស
- មិនផ្តល់ការធានា ១០០% (អតិបរមាត្រឹម ៨០%) ដើម្បីឱ្យ PFI ចូលរួមខាតបង់ ប្រសិនបើកម្ចីដែលមានការធានាត្រូវបានបាត់បង់

*បន្តនៅទំព័របន្ទាប់*

- ទូទាត់សំណងលើកម្ចីដែលខូច ជាពីរដំណាក់កាល ដើម្បីត្រួតពិនិត្យពីការខិតខំរបស់ PFIs ក្នុងការដោះស្រាយកម្ចីដែលខូច
- ត្រួតពិនិត្យ និងផ្តល់ការប្រឹក្សាយ៉ាងជិតដល់ ដល់ PFIs ក្នុងការដោះស្រាយកម្ចីដែលមិនដំណើរការ រួមទាំងការរៀបចំឥណទានឡើងវិញ ដើម្បីទប់ស្កាត់កម្ចីពីការបាត់បង់។

ហានិភ័យការជ្រើសរើស និងហានិភ័យចិត្តសាស្ត្រធ្ងន់ធ្ងរអាចបណ្តាលឱ្យមានអស្ថិរភាពនៃទីផ្សារហិរញ្ញវត្ថុតែម្តង។ ជាក់ស្តែង ស្ថាប័នហិរញ្ញវត្ថុ អាចលក់ផលិតផលហិរញ្ញវត្ថុដែលមានភាពស្មុគស្មាញ ដល់វិនិយោគិនដែលមិនមានព័ត៌មានស្មើគ្នាក្នុងការកំណត់តម្លៃឱ្យបានត្រឹមត្រូវ ដែលឆ្លុះបញ្ចាំងពីកម្រិតហានិភ័យនៃផលិតផលហិរញ្ញវត្ថុនោះ។ ម្យ៉ាងទៀត ស្ថាប័នហិរញ្ញវត្ថុដែលមានសារៈសំខាន់ជាប្រព័ន្ធ និងមិនអាចដួលរលំបាន អាចនឹងធ្វើសកម្មភាពវិនិយោគដែលមានហានិភ័យខ្ពស់ ដើម្បីទទួលបានទិន្នផលខ្ពស់ (ហានិភ័យខ្ពស់ ទិន្នផលខ្ពស់) ព្រោះផលដែលទទួលបាន គឺស្ថាប័នហិរញ្ញវត្ថុនោះជាអ្នកទទួលយក ប៉ុន្តែការខាតបង់គឺរដ្ឋាភិបាលត្រូវបង្ខំចិត្តរ៉ាប់រងជំនួស ដើម្បីចៀសវាងការដួលរំលំនៃស្ថាប័នហិរញ្ញវត្ថុនោះ ដែលអាចរាលដាលដល់ទីផ្សារហិរញ្ញវត្ថុទាំងមូល។ ករណីនេះបានកើតឡើងក្នុងអំឡុងវិបត្តិហិរញ្ញវត្ថុសកលកាលពីឆ្នាំ២០០៨ កន្លងទៅ។ ហានិភ័យការជ្រើសរើស និងហានិភ័យចិត្តសាស្ត្រមិនអាចត្រូវបានបំបាត់ទាំងស្រុងនោះទេ ប៉ុន្តែគ្រប់ភាគីពាក់ព័ន្ធ អាចសហការគ្នា ដើម្បីកាត់បន្ថយហានិភ័យនេះឱ្យនៅទាបបាន៕

## Understanding Adverse Selection and Moral Hazard

**By: Mr. No Lida, Deputy Chief Executive Officer**

EN Adverse selection and moral hazard are the problems arising from information asymmetry that can lead to market failure. Information asymmetry occurs when parties of a transaction do not have equal relevant information to execute a fair transaction. For instance, when buying a second-hand car, the buyer does not know its defects as much as the owner does. The owner would know an underlying price for his car, while the buyer may not have equal information to negotiate down to a fair price that best matches the car's true value. In this case, the information asymmetry can lead to second-hand car market failure by preventing the buying-selling transaction from happening because the buyer believes whatever price the seller agrees to sell would be more advantageous to the seller. Information asymmetry is the term coined by Nobel Prize winner economist George Akerlof in 1970.

Information asymmetry can be observed in different types of transaction. In bank loans, borrowers generally know better about their own repayment capacity than the bank from which they seek the loans, making it difficult for the banks to determine a fair price (i.e., interest rate) that best suits the borrower's creditworthiness. In a credit guarantee, information asymmetry is when a lending institution that seeks guarantees on loans has more information about the loans and the borrowers than the credit guarantor. Information asymmetry can lead to two problems – adverse selection and moral hazard.

When there is an information asymmetry, the banks might be unable to distinguish between bad and good borrowers. Facing this risk, the banks may set an interest rate that is too high for good borrowers. Good borrowers will then leave the market; only bad borrowers remain to seek loans. This is called adverse selection. As such, one way to increase credit market efficiency is to narrow the information gap between lenders and borrowers. That is why banks usually require as much information as possible from the borrowers before lending to reduce the risk of adverse selection. Adequate, reliable, and timely information about the borrowers would help the banks to narrow information gaps and offer fair loan conditions that can make both parties better off. Similarly, an adverse selection in credit guarantee is the risk that the lending institution, having better information about the borrowers and loans, only selects the bad loans for guarantees from a credit guarantee institution.

In addition, information asymmetry can also lead to moral hazard which occurs when one party of the contract engages in a reckless activity that may put the other party in an unfavorable position. In credit guarantee, a moral hazard is when a lending institution whose loans are guaranteed by a credit guarantee institution spends less effort to take care of the guaranteed loan because the default will be mainly borne by the credit guarantee institution. Likewise, a moral hazard can result from a situation where the borrower has less incentive to repay the loan, knowing that the loan is guaranteed by a third party.

The moral hazard and adverse selection are serious problems that can cause a failure of the credit guarantee scheme if not carefully addressed. As a credit guarantee institution, CGCC is particularly prone to these risks. To mitigate these, CGCC has implemented on the following key policies:

- Require Participating Financial Institutions (PFIs) to approve the loan first based on their loan approval policy before submitting the loan for CGCC's guarantee to reduce the adverse selection by the PFIs.
- Not provide a 100% guarantee (only up to 80%) to let PFIs have some skin in the game.
- Require the PFIs to monitor guaranteed loans the same way they monitor their non-guaranteed loans.
- Closely monitor and consult the PFIs on taking recovery action, including loan restructuring, to prevent the guaranteed loan status from deteriorating.
- Pay the claim in two phases to monitor PFI's efforts in guaranteed loan recovery.

A serious adverse selection and moral hazard can also lead to financial instability. A financial institution with better information may sell complicated financial assets to investors who do not have equal information to determine a fair price for the assets. Besides, financial institutions, considered to be systematically important financial institutions (SIFI) and too big to fail, may have incentives to engage in risky investment for high returns because the reward is for them to take, but their failure is for the Government to bail out to prevent the adverse spillover to the financial market. This episode occurred during the global financial crisis in 2008. It is impossible to eliminate adverse selection and moral hazard; however, relevant parties can work to minimize them.

# ជួបជាមួយម្ចាស់អាជីវកម្មដែលទទួលបានកម្ចីដែលមានការធានាពី CGCC | Meet the Business Owner Who Received a Loan Guaranteed by CGCC

លោកស្រី ប៉ែន បុប្ផា នាយិកាមជ្ឈមណ្ឌលបណ្តុះបណ្តាលឫទ្ធិពល






KH ដោយមើលឃើញថាការយល់ដឹងអំពីហិរញ្ញវត្ថុរបស់ប្រជាជនកម្ពុជាយើងនៅមានកម្រិត ហើយការប្រើប្រាស់និងការចាត់ចែងហិរញ្ញវត្ថុរបស់ពួកគាត់មិនសូវមានប្រសិទ្ធភាព នាងខ្ញុំនិងស្វាមីក៏ចាប់ផ្តើមបង្កើតក្រុមហ៊ុនឫទ្ធិពលនេះឡើងក្នុងឆ្នាំ២០១២ ដើម្បីផ្សព្វផ្សាយអំពីចំណេះដឹងហិរញ្ញវត្ថុ ក៏ដូចជាប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុផងដែរ។ រហូតមកដល់ឆ្នាំ២០២០ អាជីវកម្មរបស់ពួកយើងបានរងផលប៉ះពាល់មួយចំនួនពីវិបត្តិសកល គឺជម្ងឺកូវីដ-១៩ ប៉ុន្តែពួកយើងក៏នៅតែអាចឆ្លងកាត់បានមកដល់បច្ចុប្បន្ន។ កត្តាដែលលំបាកបំផុតនាពេលនោះគឺបញ្ហាខ្វះដើមទុន ជាពិសេសទុនបង្វិល ដើម្បីទ្រទ្រង់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ។ នៅពេលនោះយើងបានប្រើប្រាស់ទ្រព្យរបស់យើងធ្វើជាទ្រព្យធានា ដើម្បីស្នើសុំកម្ចី ប៉ុន្តែពួកយើងនៅតែមិនអាចទទួលបានទុនគ្រប់គ្រាន់តាមតម្រូវការ។ ដំណោះស្រាយដ៏ល្អនាពេលនោះគឺមានការណែនាំពី ខេមា មីក្រូហិរញ្ញវត្ថុ ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុដៃគូរបស់ CGCC ឲ្យពួកយើងស្នើសុំកម្ចីដែលមានការការធានាពីCGCCសម្រាប់អាជីវកម្មដោយមិនចាំបាច់មានទ្រព្យធានាគ្រប់គ្រាន់។

បន្ទាប់ពីទទួលបានទុនបង្វិលដែលមានការធានា យើងក៏អាចដោះស្រាយបញ្ហាសំខាន់ៗជាច្រើនដូចជាការចំណាយលើការធ្វើទីផ្សារ ការផ្សព្វផ្សាយនិងការចំណាយលើប្រត្តិបត្តិការអាជីវកម្មទាំងមូល។ យើងខ្ញុំបានពង្រីកអាជីវកម្មឲ្យធំជាងមុន មានបុគ្គលិកច្រើនជាងមុន អតិថិជនបានទទួលជ្រាប និងស្គាល់រួមជាមួយនឹងការប្រើប្រាស់សេវាកម្មរបស់យើងខ្ញុំបានកើនឡើងជាលំដាប់។ ម្យ៉ាងទៀត យើងខ្ញុំក៏មានពេលវេលាច្រើនជាងមុន ដើម្បីគិតគូរទៅលើយុទ្ធសាស្រ្តថ្មីៗបន្ថែមទៀតដោយលែងបារម្ភពីបញ្ហាដើមទុនតទៅទៀត។

ដើម្បីឲ្យអាជីវកម្មមួយជោគជ័យទៅបានគឺអាស្រ័យលើកត្តាជាច្រើនក្នុងនោះដើមទុន ឬក៏ទុនបង្វិលគឺជាកត្តាសំខាន់បំផុតសម្រាប់អាជីវកម្មនីមួយៗ។ យើងខ្ញុំសូមអរគុណដល់រាជរដ្ឋាភិបាលដែលបានបង្កើត CGCC ឡើង និងបានជួយគាំទ្រដល់អាជីវកម្មរបស់យើងខ្ញុំ ក៏ដូចជាម្ចាស់អាជីវកម្មដ៏ទៃផ្សេងទៀត ឲ្យមានឱកាសរីកចម្រើនទៅបានយ៉ាងរលូន ក៏ដូចជាដើម្បីភាពរីកចម្រើននៃសេដ្ឋកិច្ចប្រទេសជាតិទាំងមូលផងដែរ៕

EN Seeing that the financial awareness of Cambodian people is still limited, and their use and management of finances are not very effective, my husband and I started this company RithyPul in 2012 to spread the knowledge and share financial advice. Until 2020, our business was affected by the COVID-19, however we can still get through it until today. The most difficult factor at that time was the lack of working capital to support day-to-day business operations. At that time, we used our property as collateral to apply for a loan, but we still could not get enough capital as needed. The best solution at that time was to have a CGCC's Participating Financial Institution, CAMMA Microfinance, advising us to apply for a CGCC guaranteed loan for our business, which would allow us to obtain a loan without collateral to use as working capital.

After obtaining guaranteed loans from Participating Financial Institution of CGGC, we are also able to address several key issues such as marketing, advertising, and overall business operation costs. We have expanded our business with more staff, and customers becoming more aware and acquainted with the use of our services has increased steadily. On the other hand, we also have more time to think about new strategies without having to worry about capital issues.

The success of a business depends on many factors, including having enough working capital, that is the most important factor for every business. We would like to thank the Government for establishing CGCC to support our business and other MSMEs on access to finance, as well as to improve financial inclusion in the country.

# ការស្វែងយល់អំពីការធានាឥណទានលើសញ្ញាបណ្ណរបស់ក្រុមហ៊ុន Danajamin ប្រទេសម៉ាឡេស៊ី
## Understanding of Bond Guarantee of DanaJamin Malaysia

**ដោយ៖ លោក ម៉ៅ ឌីណា បុគ្គលិកជាន់ខ្ពស់ផ្នែកអភិវឌ្ឍផលិតផល | By: Mr. Mao Dina, Senior Executive of Product Development**




KH ក្រុមហ៊ុន Danajamin ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៩ ដោយក្រសួងសេដ្ឋកិច្ចម៉ាឡេស៊ី (ភាគហ៊ុន ៥០%) និងសាជីវកម្មធានាឥណទានម៉ាឡេស៊ី (ភាគហ៊ុន ៥០%) ក្នុងគោលបំណងដើម្បីសម្របសម្រួល និងបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន សម្រាប់អាជីវកម្ម នៅក្នុងទីផ្សារទុនរបស់ម៉ាឡេស៊ី។ ក្រុមហ៊ុន Danajamin មានចក្ខុវិស័យគាំទ្រសហគ្រាសអាជីវកម្មរបស់ម៉ាឡេស៊ី ក្នុងការស្វែងរកដើមទុននៅក្នុងទីផ្សារទុន ដើម្បីរួមចំណែកជួយឱ្យសេដ្ឋកិច្ចមានភាពរីកចម្រើនប្រកបដោយនិរន្តរភាព។ ក្នុងន័យនេះ Danajamin មានបេសកកម្ម ក្នុងការកសាងភាពជឿជាក់ និងទំនុកចិត្តរវាងក្រុមហ៊ុន និងវិនិយោគិន តាមរយៈការធានាឥណទាន។

ក្នុងនាមជាក្រុមហ៊ុនធានាលើការបោះផ្សាយសញ្ញាបណ្ណដែលគ្រប់គ្រងដោយរដ្ឋាភិបាលម៉ាឡេស៊ី Danajamin ត្រូវបានវាយតម្លៃចំណាត់ថ្នាក់ឥណទាន “AAA” ដោយក្រុមហ៊ុន RAM Rating Services Berhad (RAM) និង Malaysia Rating Corporation Berhad (MARC)។ គិតត្រឹមឆ្នាំ ២០២០ ក្រុមហ៊ុន Danajamin បានផ្តល់ការធានាលើការបោះផ្សាយសញ្ញាបណ្ណបានចំនួន ១០,៧ ប៊ីលាន រីងហ្គីត (ប្រហែល ២២,៩១ លានដុល្លារ) ដែលបានជួយការកៀរគរទុនពីទីផ្សារបានចំនួន ២២,៨ ប៊ីលាន រីងហ្គីត (ប្រហែល ៤៨,៨២ លានដុល្លារ) និងមានក្រុមហ៊ុនចំនួន ២៤ បានបញ្ចប់ភារកិច្ច និងអនុវត្តកិច្ចសន្យាលើការបោះផ្សាយសញ្ញាបណ្ណយ៉ាងពេញលេញ។

បច្ចុប្បន្ន ក្រុមហ៊ុន Danajamin ផ្តល់នូវគម្រោងធានាឥណទានចំនួន ៣ រួមមាន ការធានាលើធានារ៉ាប់រងហិរញ្ញវត្ថុ (Financial Guarantee Insurance), ការធានាលើវិនិយោគិន (Investor Guarantee) និងការធានាហិរញ្ញវត្ថុលើគ្រឿងបរិក្ខារ (Financing Facilities Guarantee) ក៏ដូចជាគម្រោងធានាឥណទានរបស់រដ្ឋាភិបាលលើ គម្រោងហិរញ្ញវត្ថុលើបច្ចេកវិទ្យាបៃតង (Green Technology Financing Scheme)។ វិស័យចម្បងដែលក្រុមហ៊ុន Danajamin ផ្តោតសំខាន់រួមមាន កសិកម្ម, ផ្លូវថ្នល់ និងផ្លូវល្បឿនលឿន, អចលនទ្រព្យ, ការអភិវឌ្ឍអចលនទ្រព្យ, ថាមពល, ប្រេង និងសកម្មភាពទាក់ទងនឹងឧស្ម័ន, ការអប់រំ,ផលិតផលប្រើប្រាស់ប្រចាំថ្ងៃ,ការសាងសង់,និងសម្ភារៈសាងសង់អាគារ។

EN Danajamin National Berhad was established in 2009 and is jointly owned by the Ministry of Finance of Malaysia (50%) and Credit Guarantee Corporation Malaysia Berhad (50%) to provide credit enhancements and facilitate businesses to access the Malaysian debt capital market. Danajamin’s vision is to support Malaysian corporates accessing capital in the market which will contribute to sustainable economic growth. In this regard, Danajamin mission is to build trust and confidence between companies and investors through financial guarantees.

As a bond guarantee institution owned by Malaysia Government, Danajamin is rated “AAA” by both RAM Rating Services Berhad (RAM) and Malaysia Rating Corporation Berhad (MARC). As of 2020, Danajamin provided a guaranteed bond of RM 10.7 billion (equivalent to USD 22.91 million) with a cumulative market impact of RM 22.8 billion (USD 48.82 million), and 24 companies graduated and fully redeemed their bond issuances.

Currently, Danajamin offers three essential products, including Financial Guarantee Insurance (FGI), Investor Guarantee (IG) and Financing Facilities Guarantee (FFG), and a government scheme on Green Technology Financing Scheme (GTFS 3.0). Its priority sectors are Agriculture, Toll roads and highways, Real estate, Property Development, Power, Oil and gas-related activities, Education, Consumer related products, Construction,

Source: Danajamin Annual report 2020

# CGCC នៅលើសារព័ត៌មាននានា | CGCC on the News



### Credit Guarantees to SMEs Reach $113 Million

News Article in English from Khmer Times, published on 25 April 2023: https://bit.ly/3JCKruC



### CGCC Provides $120M Credit Guarantees to Biz

News Article in English from Khmer Times, published on 19 May 2023: https://bit.ly/3NROnub




### សភាពាណិជ្ជកម្មកម្ពុជា ប្រកាសភាពជាដៃគូយុទ្ធសាស្រ្ត ជាមួយ សាជីវកម្មធានាឥណទានកម្ពុជា

### Credit Guarantee SOE, Top Trade Body in MSME Tie-up

អត្ថបទព័ត៌មានជាភាសាខ្មែរពីសារព័ត៌មាន CNC ចេញផ្សាយថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣: https://bit.ly/46uy2mi

News Article in English from Phnom Penh Post, published on 30 April 2023: https://bit.ly/3pvLVQA




### Credit Guarantee Corporation of Cambodia Partners with Cambodia Chamber of Commerce to Hit Aim of $100M in Loans for 2023

News Article in English from Cambodia Investment Review, published on 02 May 2023: https://bit.ly/3PB4BsR




### ធនាគារ មេយប៊ែង សាជីវកម្មធានាឥណទានកម្ពុជា BNI Super និង សមាគមសហគ្រិនស្ត្រីកម្ពុជា ចុះ MoU ដើម្បីលើកស្ទួយការកសាង សមត្ថភាព និងជំនាញរបស់ SME

### Maybank Cambodia, CGCC, BNI, CWEA ink MoU to Elevate SME Capacity and Capability Building

អត្ថបទព័ត៌មានជាភាសាខ្មែរពីសារព័ត៌មាន Fresh News ចេញផ្សាយថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣: https://bit.ly/3PxnCfJ

អត្ថបទព័ត៌មានជាភាសាខ្មែរពីសារព័ត៌មានកោះសន្តិភាព ចេញផ្សាយថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣: https://bit.ly/3CPTpAW

News Article in English from Khmer Times, published on 11 June 2023: https://bit.ly/434NEKB

## ផលិតផលឥណទានដែលមានការធានាពី CGCC របស់ PFIs | Guarantee Product from Our PFIs

### ហិរញ្ញប្បទានខ្សែសង្វាក់សាជីវកម្ម

ហិរញ្ញប្បទានខ្សែសង្វាក់សាជីវកម្មត្រូវបានតាក់តែងឡើងដើម្បីផ្តល់ជូនដល់អតិថិជននូវកញ្ចប់ហិញ្ញប្បទាននៅក្នុងរង្វង់នៃតម្រូវការដើមទុនអាជីវកម្ម។ អាទិភាពទៅលើអតិថិជនគោលដៅគឺសហគ្រាសខ្នាតតូចនិងមធ្យមដែលមានសក្តានុពលក្នុងតម្រូវការសេវាហិរញ្ញវត្ថុ, ជាពិសេស កម្ចីនិងសេវាកម្មផ្សេងៗទៀត ដើម្បីគាំទ្រដល់ប្រតិបត្តិការអាជីវកម្មរបស់ពួកគេ។

លក្ខណៈពិសេសនិងអត្ថប្រយោជន៍ផលិតផល៖

| លក្ខណៈពិសេស | បរិយាយ |
|---|---|
| រូបិយប័ណ្ណ | រៀល និង ដុល្លារ |
| អត្រាការប្រាក់ប្រចាំខែ | ១១.៥%-១៥% ក្នុង១ឆ្នាំ |
| ទំហំកម្ចី | ទៅដល់ ៣០០,០០០ដុល្លារ |
| រយៈពេលកម្ចី | ដល់៩៦ខែ |
| របៀបបង់សង | បត់បែនតាមតម្រូវការអតិថិជន |
| ប្រភេទនៃទ្រព្យធានា | បត់បែនតាមតម្រូវការអតិថិជន |

*អត្ថប្រយោជន៍៖*

- ឱកាសទទួលបានកម្ចីដោយមិនមានដាក់ទ្រព្យធានា
- បង្កើនទំនាក់ទំនងល្អជាមួយដៃគូរអាជីវកម្មប្រកបដោយនិរន្តរភាព
- បង្កើនបរិមាណលក់និងចំណូលដោយមិនចាំបាច់ប្រើដើមទុនផ្ទាល់ខ្លួន

*សម្រាប់ព័ត៌មានបន្ថែម៖*

សូមអញ្ជើញទៅកាន់សាខារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ ណាមួយដែលនៅជិតលោកអ្នកបំផុតឬ

- ទូរស័ព្ទទៅលេខ ០២៣ ២២០ ២០២ ឬ ១៨០០ ២០០ ២០០ ឬ
- អ៊ីម៉ែលមកកាន់ customerservice@amkcambodia.com

### ផលិតផលឥណទានសម្រាប់សហគ្រាសធុនតូច ឬមធ្យម ពីធនាគារ J-Trust Royal




តើលោកអ្នកមានបំណងចង់ពង្រីកអាជីវកម្មរបស់លោកអ្នក និងកំពុងស្វែងរកនូវកម្ចីអាជីវកម្ម ប៉ុន្តែមិនមានទ្រព្យធានាគ្រប់គ្រាន់? ធនាគារ J Trust Royal គឺជាដៃគូដ៏សក្តិសមបំផុតសម្រាប់លោកអ្នក។ ធនាគារ J Trust Royal ផ្នែកសហគ្រាសធុនតូចនិងមធ្យម តែងតែទុកអតិថិជនជាចំបង។ យើងផ្តោតទៅលើការផ្តល់នូវបទពិសោធន៍សេវាកម្មធនាគារ ដែលមានភាពងាយស្រួលទៅកាន់អតិថិជន។ អនុញ្ញាតអោយយើងនឹងក្លាយជាផ្នែកមួយនៃការរីកចម្រើនរបស់អាជីវកម្មលោកអ្នក។

| លក្ខណៈពិសេស | |
|---|---|
| ទំហំកម្ចី | រហូតដល់ទៅ USD ១,០០០,០០០.០០ |
| រយៈពេលកម្ចី | រហូតដល់ទៅ ៨៤ ខែ |
| របៀបទូទាត់សង | ការទូទាត់សងប្រកបដោយភាពបត់បែនដើម្បីស្របតាមតម្រូវការរបស់អាជីវកម្មលោកអ្នក |
| អត្រាការប្រាក់ | មានភាពប្រកួតប្រជែង |
| រូបិយប័ណ្ណ | រៀល និងដុល្លារ |

*បន្តនៅទំព័របន្ទាប់*

*សម្រាប់ព័ត៌មានបន្ថែម៖*

សូមទំនាក់ទំនងទៅកាន់ផ្នែកបម្រើសេវាអតិថិជនរបស់ធនាគារ J Trust Royal អំពីនីតិវិធីនៃការស្នើសុំកម្ចី និងលក្ខខណ្ឌផ្សេងទៀត តាមរយៈ

- ទូរស័ព្ទលេខ ០៩៥ ៥៥៥ ៦៧១ (តេឡេក្រាម) ឬ Hotline ៖ ០២៣ ៩៩៩ ២៥៥ (ក្នុងម៉ោងធ្វើការ)
- សម្រាប់អាសយដ្ឋានសាខាធនាគារ J Trust Royal សូមចូលទៅកាន់
- គេហទំព័រ https://jtrustroyal.com/en/personal/

## កម្មវិធីឥណទានទូទាត់អាជីវកម្មជាមួយ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី**
**LOLC (Cambodia) Plc.**

អិលអូអិលស៊ី ផ្តល់ជូនសេវាកម្មដែលមានស្តង់ដារ និងផលិតផលដែលមានគុណភាពខ្ពស់។ ពួកយើងក៏តែងតែនៅជិត ដើម្បីជួយអតិថិជនក្នុងការស្វែងយល់បន្ថែមពីរបៀបប្រើប្រាស់ផលិតផល និងសេវាកម្មនីមួយៗ។ ដើម្បីជួយដល់អាជីវកម្មខ្នាតតូច មធ្យម និងខ្នាតធំ ក្នុងការពង្រីកលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់ជាទុនបង្វិល និងពង្រីកអាជីវកម្ម អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី បានសហការជាដៃគូជាមួយនិងសាជីវកម្មធានាឥណទានកម្ពុជា (CGCC) ដើម្បីផ្តល់ឥណទាន ជូនអតិថិជនដែលមានអាជីវកម្ម សហគ្រាសខ្នាតតូច និងមធ្យម ដែលមានលទ្ធភាពសងតែខ្វះទ្រព្យធានា សម្រាប់ប្រើប្រាស់ជាទុនវិនិយោគ ទុនបង្វិលនិងការពង្រីកអាជីវកម្ម។

លក្ខណៈពិសេសនៃកម្មវិធីឥណទានទូទាត់អាជីវកម្ម៖




| រូបិយប័ណ្ណ | ទំហំប្រាក់កម្ចី | អត្រាការប្រាក់ប្រចាំខែ | រយៈពេល | របៀបបង់សង |
|---|---|---|---|---|
| ប្រាក់រៀល | រហូតដល់ ៨០០.០០០.០០០ | ១,២% - ១,៥% | រហូតដល់ ៨៤ ខែ | ប្រាក់កម្ចីមានច្រើនជម្រើសតាមតម្រូវការរបស់អតិថិជន |
| ប្រាក់ដុល្លារ | រហូតដល់ ២០០.០០០ | ១,២% - ១,៥% | រហូតដល់ ៨៤ ខែ | |

*សម្រាប់ព័ត៌មានបន្ថែម និងរបៀបដាក់ពាក្យស្នើសុំកម្ចី៖*

ដើម្បីស្នើសុំប្រាក់កម្ចី អតិថិជន អាចអនុវត្តតាមជំហានងាយស្រួលខាងក្រោម៖

- ជួបជាមួយបុគ្គលិក អិលអូអិលស៊ី នៅក្នុងតំបន់របស់លោកអ្នក ឬនៅការិយាល័យ អិលអូអិលស៊ី ដែលជិតបំផុត ឬក៏អាចធ្វើការទំនាក់ទំនងតាមរយៈ
- លេខទូរសព្ទ ០២៣ ៩៩១ ៩៩១ ឬតាមរយៈ
- គេហទំព័រ www.lolc.com.kh
- ស្នើសុំចំនួនទឹកប្រាក់ជាក់លាក់ និងរយៈពេលទៅតាមតម្រូវការក្នុងក្រុមរបស់លោកអ្នក។

## PFIs របស់ CGCC ដែលបានស្នើសុំការធានាឥណទានកន្លងមក | Our Active PFIs

**ACLEDA BANK**
Tel: 023 998 777
Email: acledabank@acledabank.com.kh
Web: www.acledabank.com.kh

**APD BANK – ASIA-PACIFIC DEVELOPMENT BANK**
Tel: 023 211 888
Email: ccc@apdbank.com.kh
Web: www.apdbank.com.kh

**CAMBODIAN PUBLIC BANK**
Tel: 023 428 100
Email: CustomerService@campubank.com.kh
Web: www.campubank.com.kh

**CAB BANK – CAMBODIA ASIA BANK**
Tel: 023 980 000
Email: sale@cab.com.kh
Web: www.cab.com.kh

**CAMBODIA POST BANK PLC.**
Tel: 023 260 888
Email: info@cambodiapostbank.com
Web: www.cambodiapostbank.com

**CANADIA BANK**
Tel: 023 868 222
Email: contact@canadiabank.com.kh
Web: www.canadiabank.com.kh

**CIMB BANK**
Tel: 023 988 388
Email: customercare@cimb.com.kh
Web: www.cimbbank.com.kh

**FTB – Foreign Trade Bank of Cambodia**
Tel: 023 862 111
Email: info@ftbbank.com
Web: www.ftbbank.com

**Maybank**
Tel: 098 888 028
Email: contactus.mcp@maybank.com
Web: www.maybank2u.com.kh

**PhillipBank**
Tel: 086 930 000
Email: info@phillipbank.com.kh
Web: www.phillipbank.com.kh

**RHB**
Tel: 023 992 833
Email: hello@rhbgroup.com
Web: www.rhbgroup.com.kh

**SATHAPANA BANK**
Tel: 023/081 992 010
Email: customercare@sathabana.com.kh
Web: www.sathapana.com.kh

**ABA BANK – NATIONAL BANK OF CANADA GROUP**
Tel: 023 225 333
Email: info@ababank.com
Web: www.ababank.com

**AMK**
Tel: 023 220 202
Email: customerservice@amkcambodia.com
Web: www.amkcambodia.com

**CAMMA MICROFINANCE**
Tel: 023 533 9999
Email: info@camma.com.kh
Web: www.camma.com.kh

**CHIP MONG BANK**
Tel: 081 811 911
Email: info@chipmongbank.com
Web: www.chipmongbank.com/en

**ចំរើន (Chamroeun)**
Tel: 023 959 777
Email: info@chamroeun.com
Web: www.chamroeun.com

**J Trust Royal Bank**
Tel: 023 999 000
Email: ccc@jtrustroyal.com
Web: www.jtrustroyal.com

**LOLC**
Tel: 023 991 991
Email: info@lolc.com
Web: www.lolc.com.kh

**PRINCE BANK**
Tel: 1800-20-8888
Email: info@princebank.com.kh
Web: www.princebank.com.kh

**Wing**
Tel: 023 999 0989
Email: care.centre@wingmoney.com
Web: www.wingmoney.com

បើលោកអ្នកមានជាមតិយោបល់ដើម្បីកែលម្អ ព្រឹត្តិបត្រព័ត៌មានរបស់ CGCC សូមទំនាក់ទំនង មកក្រុមការងាររបស់យើងខ្ញុំតាមរយៈ

023 722 123 | Info@cgcc.com.kh

# បង្កើនបរិយាបន្នហិរញ្ញវត្ថុ និងអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា

# Improve Financial Inclusion and Develop SMEs in Cambodia

www.cgcc.com.kh


023 722 123

info@cgcc.com.kh

www.cgcc.com.kh

សាជីវកម្មធានាឥណទានកម្ពុជា CGCC

សាជីវកម្មធានាឥណទានកម្ពុជា
Credit Guarantee Corporation of Cambodia

Credit Guarantee Corporation of Cambodia (CGCC)

Business Development Center, 19th Floor, OCIC Blvd,
Sangkat Chroy Changvar, Khan Chroy Changvar, Phnom Penh, Cambodia.